## អបអរសាទរទិវា

# វប្បធម៌ជាតិ ៣មីនា

### លើកទី២៦ ឆ្នាំ២០២៤





រក្សាសិទ្ធិ៖ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ២០២៤

គំនូរក្របមុខ៖ ហាន សុខលី, ២០២៤

# មាតិកា

សារាចរស្តីពីការរៀបចំទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៦ ឆ្នាំ២០២៤ ក

## វប្បធម៌រួមចំណែកអភិវឌ្ឍសង្គមនិងលើកស្ទួយកិត្យានុភាពជាតិ

- ព្រះរាជពិធីបួងសួងសុំព្រះអគ្គិកីឡា និងសិល្បៈទស្សនីយភាពអបអរកីឡាស៊ីហ្គេម លើកទី៣២ និងកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ២
- ពិធីសម្ពោធស្ពានហាលប្រាសាទអង្គរវត្ត ៥
- សន្និសីទអន្តររដ្ឋាភិបាលលើកទី៤ ស្តីពី “រមណីយដ្ឋានអង្គរ-សំបូរព្រៃគុក” ៨
- ការយាងនិវត្តមកកាន់មាតុភូមិនៃមរតកដូនតា៖ ពិធីទទួលវត្ថុបុរាណខ្មែរនៅវិមានសន្តិភាព ១១
- អបអរសាទររមណីយដ្ឋានប្រាសាទកោះកេរចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ១៥
- អបអរសាទរទីក្រុងបាត់ដំបងចុះក្នុងបញ្ជី “បណ្តាញទីក្រុងច្នៃប្រតិដ្ឋអង្គការយូណេស្កូ” ១៩
- ជំនាញវិជ្ជាជីវៈដូនតា៖ ថ្នាលបណ្តុះវប្បធម៌ជាតិ ២២
- ព្រឹត្តិការណ៍ “រម្លឹកគុណអង្គរ” បណ្តុះស្មារតីយុវជនឱ្យស្រឡាញ់មរតកវប្បធម៌ជាតិ ២៥

## ការអភិរក្សនិងផ្សព្វផ្សាយមរតកវប្បធម៌អរូបី

- “សរសេរបំណាន អានបំណាប់ ចាប់យកចំណេះ”៖ ពិព័រណ៍សៀវភៅកម្ពុជា លើកទី១០ ឆ្នាំ២០២៣ ២៨
- “សំណេរអង្គរ”៖ ការប្រឡងសរសេរតាមអានថ្នាក់ជាតិជាសាធារណៈ ៣១
- ការគិតគូររបស់កម្ពុជាក្នុងការចូលរួមអភិវឌ្ឍវិស័យសិប្បកម្មនិងវប្បធម៌-សិល្បៈនៅអាស៊ីអាគ្នេយ៍ក្រោយការរីករាលដាលនៃជំងឺកូវីដ-១៩ ៣៣
- មរតកកែវមណីមេខលា៖ ការបងចាំ ការផ្ទេរចំណេះដឹង និងការបន្តវេននៃរបាំព្រះរាជទ្រព្យ ៣៦
- បេតិកភណ្ឌឯកសារកម្ពុជា៖ ការរក្សាទុកការបងចាំពីអតីតកាល ៣៩

## ការអភិរក្សនិងផ្សព្វផ្សាយមរតកវប្បធម៌រូបី

- ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយនៅបុរាណដ្ឋានប្រាសាទសំបូរព្រៃគុក ៤៤
- កំណាយស្រាវជ្រាវនៅបុរាណដ្ឋានទួលកុកក្រួស ៤៧
- រាជធានីកោះកេរ និងសហគមន៍មនុស្សរស់នៅសម័យបុរាណ ៥១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០១ សរ

# សារាចរ
## ស្តីពី
## ការរៀបចំទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៦ ឆ្នាំ២០២៤

អនុវត្តតាមស្មារតីអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតទិវាវប្បធម៌ជាតិ និងស្របតាមទិសស្លោក «**កម្ពុជា : ព្រះរាជាណាចក្រនៃវប្បធម៌**» រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី៣ ខែមីនា ជារៀងរាល់ឆ្នាំសម្រាប់រៀបចំប្រារព្ធ «**ទិវាវប្បធម៌ជាតិ**» នៃព្រះរាជាណាចក្រកម្ពុជា។ ទិវាវប្បធម៌ជាតិ គឺជាទិវាដ៏មានសារៈសំខាន់មួយរបស់ប្រជាជាតិកម្ពុជា ដើម្បីរំលឹកដល់គុណូបការៈបុព្វបុរសខ្មែរគ្រប់ជំនាន់ដែលបានលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត បញ្ញាស្មារតី និងអាយុជីវិត ក្នុងការបង្កើត ថែរក្សា និងការពារសម្បត្តិវប្បធម៌ដ៏សម្បូរបែបនិងមានតម្លៃមិនអាចកាត់ថ្លៃបាន បន្សល់ទុកមកដល់កូនចៅជំនាន់ក្រោយ។ ទន្ទឹមគ្នានេះដែរ ទិវាវប្បធម៌ជាតិ ក៏ជាឱកាសដ៏មានតម្លៃដើម្បីចូលរួមបំផុសនូវមនសិការស្រឡាញ់សិល្បៈវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី និងកេរដំណែលដូនតាជាច្រើនទៀតដែលជាដួងព្រលឹងនិងអត្តសញ្ញាណជាតិ សម្រាប់ប្រជាជនខ្មែរគ្រប់រូប ក្នុងគោលបំណងធានាឱ្យបាននូវការអភិរក្សនិងអភិវឌ្ឍវប្បធម៌ប្រកបដោយចីរភាព និងបរិយាបន្ន ស្របតាមគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

ក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់ដល់ការលើកតម្លៃចំពោះវប្បធម៌អរិយធម៌ជាតិដ៏ឧត្តុង្គឧត្តមនេះ រាជរដ្ឋាភិបាលសម្រេចរៀបចំទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៦ ឆ្នាំ២០២៤ ដោយបន្តរក្សាប្រធានបទ «**យុវជនដើម្បីវប្បធម៌ជាតិ**» ក្នុងគោលបំណងជំរុញទឹកចិត្តប្រជាជនខ្មែរទាំងក្នុងនិងក្រៅប្រទេស ជាពិសេសយុវជនបន្តវេនឱ្យចូលរួមកាន់តែសកម្មថែមទៀតក្នុងសកម្មភាពវប្បធម៌ជាតិ ដូចជា៖

- លើកកម្ពស់ស្មារតីមោទនភាពជាតិ មនសិការស្នេហាជាតិ ភាពជាម្ចាស់នៃកេរដំណែលវប្បធម៌ និងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ដោយបំផុសឱ្យប្រជាជនខ្មែរគ្រប់រូបចូលរួមជាកម្លាំងចលករក្នុងកិច្ចអភិរក្ស លើកស្ទួយ និងអភិវឌ្ឍវប្បធម៌ជាតិ រួមទាំងវប្បធម៌ចម្រុះរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ឱ្យបានស្ថិតស្ថេរគង់វង្ស រីកចម្រើន ដោយមិនប្រកាន់នូវនិន្នាការនយោបាយ ជំនឿ សាសនា ពណ៌សម្បុរ និងជាតិពន្ធុ
- បង្កើនការយល់ដឹងអំពីតម្លៃដ៏មហាសាលនៃសម្បត្តិវប្បធម៌ជាតិដ៏សម្បូរបែប ដែលជាប្រភពមិនចេះរីងស្ងួតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព តាមរយៈការបង្កើតសេវានិងផលិតផលវប្បធម៌ថ្មីៗ ក្នុងគោលដៅពាណិជ្ជកម្មនិងទេសចរណ៍ ដែលរួមចំណែកដល់ការបង្កើតការងារឱ្យកាន់តែច្រើន ដែលជួយបង្កើនប្រាក់ចំណូលនិងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនយើង
- លើកទឹកចិត្តដល់ស្មារតីសហគ្រិនភាព និងការបង្កើតការងារផ្នែកសិល្បៈវប្បធម៌នៅក្នុងចំណោមយុវជនកម្ពុជា ដើម្បីគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្មវប្បធម៌និងច្នៃប្រឌិត ដែលជាសក្តានុពលមួយនៃប្រភព

កំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ ជាពិសេសតាមរយៈការផ្ដល់ឱកាសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យដើម្បីទទួលបាននូវការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈដូនតា ក្នុងគោលបំណងធានាឱ្យបាននូវការផ្ទេរចំណេះដឹងនិងជំនាញប្រពៃណីដល់យុវជនជំនាន់ក្រោយ

- លើកកម្ពស់ភាពច្នៃប្រឌិតនិងនវានុវត្តន៍នៅក្នុងការងារអភិវឌ្ឍសិល្បៈវប្បធម៌ដោយប្រើបច្ចេកវិទ្យាឌីជីថលព្រមជាមួយនឹងគំនិតផ្ដួចផ្ដើមថ្មីៗ ដើម្បីបង្កើនភាពទាក់ទាញនិងផ្ដល់ភាពងាយស្រួលដល់ការចូលរួមក្នុងសកម្មភាពវប្បធម៌សម្រាប់សាធារណជនទូទៅ ជាពិសេស កុមារ យុវជន ស្ត្រី មនុស្សចាស់ និងជនមានពិការភាព ក្រោមទិសស្លោក «សិល្បៈវប្បធម៌សម្រាប់យើងទាំងអស់គ្នា»
- លើកស្ទួយកិច្ចសហប្រតិបត្តិការវប្បធម៌ ក្នុងស្មារតីកសាងស្ពានភ្ជាប់ទំនាក់ទំនងពីសង្គមមួយទៅសង្គមមួយពីប្រជាជាតិមួយទៅប្រជាជាតិមួយ និងពីប្រទេសមួយទៅប្រទេសមួយ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងនិងការគោរពគ្នាទៅវិញទៅមក ដែលនាំមកនូវសាមគ្គីភាព មិត្តភាព សុខដុមរមនា និងសន្តិភាព។

ដើម្បីរៀបចំទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៦ ឆ្នាំ២០២៤ នេះឱ្យបានកាន់តែទូលំទូលាយនិងផ្សព្វផ្សាយឱ្យប្រជាជនកម្ពុជាគ្រប់ស្រទាប់បានយល់ដឹងកាន់តែច្បាស់អំពីអត្ថន័យនៃទិវានេះ ក៏ដូចជាដើម្បីអាចឱ្យព្រឹត្តិការណ៍នេះប្រព្រឹត្តទៅដោយរលូន រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅៈ

១- ពេលវេលាសម្រាប់ប្រារព្ធទិវាវប្បធម៌ជាតិ លើកទី២៦ គឺត្រូវបានកំណត់យកចន្លោះចាប់ពីថ្ងៃទី៣ ខែមីនា រហូតដល់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។ ក្នុងន័យនេះ ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំកម្មវិធីនិងសកម្មភាពគាំទ្រនានា ដើម្បីប្រារព្ធទិវាវប្បធម៌ជាតិ លើកទី២៦ ទាំងនៅទីតាំងផ្ទាល់ និង/ឬនៅលើបណ្ដាញសង្គមទៅតាមពេលវេលាសមរម្យណាមួយនៅក្នុងរយៈពេលដែលបានកំណត់នេះ។

២- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវរៀបចំឯកសារពាក់ព័ន្ធដើម្បីឃោសនាផ្សព្វផ្សាយអំពីទិវាវប្បធម៌ជាតិ ហើយក៏ត្រូវណែនាំដល់អាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ អាជ្ញាធរជាតិសំបូរព្រៃគុក គ្រប់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ឱ្យរៀបចំផ្សព្វផ្សាយសមិទ្ធផលការងារសំខាន់ៗ ពាក់ព័ន្ធនឹងការអភិរក្ស ការលើកស្ទួយ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់បេតិកភណ្ឌពិភពលោក និងរមណីយដ្ឋានវប្បធម៌នានា រួមទាំងកម្មវិធីផ្សេងៗទៀត ដើម្បីអបអរទិវាវប្បធម៌ជាតិនៅមូលដ្ឋានរបស់ខ្លួន។ ទន្ទឹមគ្នានេះ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវសហការជាមួយបណ្ដាក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការ សមាគម សហគមន៍ និងវិស័យឯកជនដែលកំពុងប្រតិបត្តិការនៅក្នុងវិស័យវប្បធម៌ ដើម្បីរួមគ្នាធ្វើការផ្សព្វផ្សាយវប្បធម៌ជាតិឱ្យបានទូលំទូលាយនៅក្នុងរយៈពេលនេះផងដែរ។

៣- ក្រសួងព័ត៌មានត្រូវណែនាំដល់បណ្ដាញសារព័ត៌មានគ្រប់ប្រភេទរបស់រដ្ឋនិងឯកជនទាំងអស់ចូលរួមផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវខ្លឹមសារសកម្មភាពពាក់ព័ន្ធនឹងការអបអរទិវាវប្បធម៌ជាតិ។

៤- ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវសហការផ្សព្វផ្សាយវប្បធម៌ជាតិ និងខ្លឹមសារទិវាវប្បធម៌ជាតិដល់សិស្ស និស្សិត ព្រមទាំងបំផុសឱ្យមានសកម្មភាពបង្ហាញ និងប្រតិបត្តិប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌ជាតិ នៅតាមគ្រឹះស្ថានសិក្សាអប់រំរដ្ឋនិងឯកជន។

៥- ក្រសួងទេសចរណ៍ត្រូវផ្សព្វផ្សាយវប្បធម៌ជាតិនិងខ្លឹមសារទិវាវប្បធម៌ជាតិ ដល់ភ្ញៀវទេសចរជាតិនិងអន្តរជាតិតាមរយៈទីភ្នាក់ងារទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋានគ្រប់ប្រភេទ ពិសេសស្របតាមកម្មវិធី «ទស្សនាសៀមរាបឆ្នាំ២០២៤»។

៦- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវណែនាំដល់គ្រប់ស្ថានឯកអគ្គរាជទូត ស្ថានអគ្គកុងស៊ុល ស្ថានកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេស និងសហគមន៍ខ្មែរ

នៅបរទេស ឱ្យចូលរួមរៀបចំកម្មវិធីនិងសកម្មភាពនានា ដើម្បីប្រារព្ធទិវាវប្បធម៌ជាតិទាំងនៅទីតាំងផ្ទាល់ តាមបណ្តាញសង្គម និង/ឬតាមមធ្យោបាយផ្សេងៗទៀត។

៧- ក្រសួងធម្មការនិងសាសនាត្រូវបំផុសចលនាព្រះសង្ឃនិងគ្រប់សាសនិកឱ្យរៀបចំកម្មវិធីនិងសកម្មភាពនានា ដើម្បីផ្សព្វផ្សាយវប្បធម៌ជាតិនិងខ្លឹមសារទិវាវប្បធម៌ជាតិ នៅតាមទីអារាម វិហារសាសនា មណ្ឌលវិបស្សនា និងទីសក្ការៈផ្សេងៗ។

៨- ក្រសួងមហាផ្ទៃនិងក្រសួងការពារជាតិត្រូវណែនាំទៅអង្គភាពមូលដ្ឋាន ដើម្បីរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈក្នុងឱកាសប្រារព្ធទិវាវប្បធម៌ជាតិ លើកទី២៦ ឱ្យមានប្រសិទ្ធភាពនិងស្មារតីទទួលខុសត្រូវខ្ពស់។

៩- រដ្ឋបាលរាជធានី ខេត្តត្រូវចូលរួមជួយឧបត្ថម្ភគាំទ្រដល់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីអាចរៀបចំកម្មវិធីនិងសកម្មភាពផ្សព្វផ្សាយវប្បធម៌នៅក្នុងដែនដីរបស់ខ្លួន ដោយផ្តោតលើការអប់រំមហាជនជាពិសេសយុវជន ឱ្យមានស្មារតីកាន់តែមុតមាំថែមទៀតនៅក្នុងការចូលរួមថែរក្សា ការពារ លើកស្ទួយនិងអភិវឌ្ឍវប្បធម៌ជាតិ ព្រមទាំងរៀបចំចងបដាពាក្យស្លោកតាមទីសាធារណៈ និងការបិទគំនូរផ្សាយវប្បធម៌នៅតាមទីតាំងសំខាន់ៗក្នុងដែនរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន។

១០- គ្រប់ក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ក្រោមជាតិ សាលារៀន រោងចក្រ សហគ្រាស គេហដ្ឋាននិងសហគមន៍ខ្មែរនៅបរទេសចូលរួមប្រារព្ធនិងអបអរទិវាវប្បធម៌ជាតិ តាមមធ្យោបាយផ្សេងៗដែលមានដូចជាការលើកទង់ជាតិ ទង់ផ្ទាំង បដាពាក្យស្លោក គំនូរផ្សាយសិល្បៈវប្បធម៌ និង/ឬសកម្មភាពសមរម្យនានានៅទីតាំងរបស់ខ្លួន ក៏ដូចជាតាមបណ្តាញសង្គម។

១១- អ្នកចូលរួមកម្មវិធីនិងសកម្មភាពផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ទិវាវប្បធម៌ជាតិត្រូវស្លៀកពាក់សមរម្យតាមបែបប្រពៃណីជាតិ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ពុធ ១២ កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ពាក្យស្លោកសម្រាប់ទិវាវប្បធម៌ជាតិ ៣មីនា
# លើកទី២៦ ឆ្នាំ២០២៤

- អបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៦ ឆ្នាំ២០២៤ "យុវជនដើម្បីវប្បធម៌ជាតិ"
- កម្ពុជាៈ ព្រះរាជាណាចក្រនៃវប្បធម៌
- វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន
- វប្បធម៌ គឺជាព្រលឹង ជាអត្តសញ្ញាណ និងជាកិត្យានុភាពរបស់ជាតិ
- វប្បធម៌នាំមកនូវសន្តិភាព សុខដុមនីយកម្មសង្គម និងការអភិវឌ្ឍ
- អភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម
- លើកកម្ពស់វប្បធម៌ជាតិ ដើម្បីពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់
- ទិវាវប្បធម៌ជាតិ គឺជាទិវានៃការបងបំនិងការចូលរួមអភិរក្សវប្បធម៌ជាតិ
- វប្បធម៌ដើម្បីការអប់រំ ការអប់រំដើម្បីវប្បធម៌
- សិល្បៈវប្បធម៌សម្រាប់យើងទាំងអស់គ្នា
- យុវជនជាកម្លាំងដ៏រឹងមាំក្នុងកិច្ចអភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិ
- កិច្ចការពារវប្បធម៌ជាតិ គឺជាកាតព្វកិច្ចរបស់យើងគ្រប់ៗគ្នា
- មរតកដូនតាគឺជារតនសម្បត្តិរបស់ជាតិដែលមានតម្លៃមិនអាចកាត់ថ្លៃបាន
- រៀនបេះជំនាញដូនតា គឺស្មើនឹងការចូលរួមអភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិ
- ផ្តល់តម្លៃដល់ភាពចម្រុះនៃវប្បធម៌ គឺនាំមកនូវសុខដុមរមនានិងការឯកភាពជាតិពន្លកក្នុងសង្គម
- ប្រជាពលរដ្ឋកម្ពុជាគ្រប់ៗរូបមានសិទ្ធិចូលរួមក្នុងគ្រប់ទម្រង់នៃវិញ្ញត្តិវប្បធម៌

# វប្បធម៌រួមចំណែកអភិវឌ្ឍសង្គម
# និងលើកស្ទួយកិត្យានុភាពជាតិ

# ព្រះរាជពិធីបួងសួងសុំព្រះអគ្គិកីឡា និងសិល្បៈទស្សនីយភាពអបអរកីឡាស៊ីហ្គេម លើកទី៣២ និងកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២



ព្រះមហាក្សត្រ ប្រោសប្រទានព្រះអគ្គិកីឡាអុជបំភ្លឺគប់

“កីឡាអាស៊ីអាគ្នេយ៍” (Southeast Asian Games) ឬហៅខ្លីថា ស៊ីហ្គេម (SEA Games) បង្កើតឡើងក្នុងឆ្នាំ១៩៥៩ ដោយកាលនោះហៅថា “កីឡាឧបទ្វីបអាស៊ីអាគ្នេយ៍” (Southeast Asian Peninsula Games ឬ SEAP Games) ដែលមានស្ថាបនិក៦ប្រទេសគឺ កម្ពុជា, ថៃឡង់ដ៍, ភូមា, ម៉ាឡេស៊ី, វៀតណាម, ឡាវ។ នេះជាព្រឹត្តការណ៍ក្នុងតំបន់ដែលបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការ ការយោគយល់គ្នា និងទំនាក់ទំនងក្នុងបំណោមប្រទេសនៅអាស៊ីអាគ្នេយ៍។ កីឡានេះប្រារព្ធឡើងរៀងរាល់ពីរឆ្នាំម្តង ហើយប្រទេសថៃឡង់ដ៏បានធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាស៊ីហ្គេមលើកទី១ក្នុងខែធ្នូ ឆ្នាំ១៩៥៩ នៅទីក្រុងបាងកក។ ចំណែកកីឡាអាស៊ានប៉ារ៉ាហ្គេម (ASEAN Para Games) ជាព្រឹត្តិការណ៍កីឡាសម្រាប់ជនមានពិការភាព បង្កើតឡើងក្នុងឆ្នាំ២០០១ ដោយស្ថាបនិកទាំង១០ប្រទេសក្នុងតំបន់ ក្នុងគោលបំណងលើកកម្ពស់មិត្តភាពនិងសាមគ្គីភាព រវាងជនមានពិការភាពក្នុងតំបន់អាស៊ាន ព្រមទាំងស្តារនីតិសម្បទានិងធ្វើសមាហរណកម្មជនមានពិការភាពទៅក្នុងសង្គម។ ព្រឹត្តិការណ៍កីឡាអាស៊ានប៉ារ៉ាហ្គេមប្រារព្ធនៅរៀងរាល់ពីរឆ្នាំម្តងភ្ជាប់ជាមួយនឹងកីឡាស៊ីហ្គេម ហើយប្រទេសម៉ាឡេស៊ីធ្វើជាម្ចាស់ផ្ទះលើកដំបូងនៃការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមនៅក្នុងខែតុលា ឆ្នាំ២០០១។



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកព្រឹត្តិការណ៍កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម (ប្រភព៖ www.information.gov.kharticles103781)

ក្រោយរង់ចាំអស់រយៈពេល៦៤ឆ្នាំ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ក្រោមស្លោកថា "កីឡារស់ក្នុងសន្តិភាព"។ មុននឹងព្រឹត្តិការណ៍មកដល់ ពោលគឺនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ កម្ពុជាបានរៀបចំព្រះរាជពិធីសុំ "ព្រះអគ្គិកីឡា" ពីព្រះអាទិទេព សម្រាប់ពិធីបើកព្រឹត្តិការណ៍កីឡាជាប្រវត្តិសាស្ត្រនេះ នៅទីក្លារបែនមុខប្រាសាទអង្គរវត្ត ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតនៃ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងរៀបចំពិធីរត់ដង្ហែព្រះអគ្គិកីឡានេះនៅតាមបណ្តាប្រទេសក្នុងតំបន់អាស៊ាន និងនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាបក្នុងប្រទេសកម្ពុជា។

ពិធីបើកជាផ្លូវការនៃការប្រកួតកីឡាស៊ីហ្គេម និងកីឡាអាស៊ានប៉ារ៉ាហ្គេម ប្រព្រឹត្តទៅយ៉ាងមហោឡារិក និងប្រកបដោយមោទនភាពជាតិនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ នៅពហុកីឡដ្ឋានជាតិមរតកតេជោ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន អមដោយវត្តមានថ្នាក់ដឹកនាំ មន្ត្រីរាជការពីគ្រប់ក្រសួង-ស្ថាប័ន ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ អ្នកសារព័ត៌មានក្នុងនិងក្រៅប្រទេស ព្រមទាំងប្រជាពលរដ្ឋសរុបប្រមាណជាងប្រាំមួយម៉ឺននាក់។

អ្វីដែលធ្វើឱ្យពិធីបើកព្រឹត្តិការណ៍កីឡាជាប្រវត្តិសាស្ត្រនេះកាន់តែអធិកអធមថែមទៀតនោះគឺការសម្តែងសិល្បៈទស្សនីយភាពដ៏គគ្រឹកគគ្រេងអស្ចារ្យដែលរៀបចំឡើងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អំពី "ដំណើរជាតិកម្ពុជា" រៀបរាប់ចាប់តាំងពីការកកើតនគរខ្មែរ, ភាពរុងរឿងថ្កុំថ្កើងនៃអាណាចក្រអង្គរ, ភាពបម្រើនលូតលាស់គ្រប់វិស័យនិងសុខសន្តិភាព ស្ថិតក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងការរួបរួមសាមគ្គីនៃបណ្តាប្រជាជាតិអាស៊ានក្រោមស្លោក "សហគមន៍ជោគវាសនាតែមួយ"។ ទស្សនីយភាពដ៏ត្រកាលនេះបូលរួមសម្តែងដោយសិល្បករទាំងក្នុងនិងក្រៅប្រព័ន្ធ និងកងកម្លាំងប្រដាប់អាវុធសរុបចំនួន៣២៩២នាក់ ហើយបានធក់យកបេះដូងប្រជាពលរដ្ឋ ប្រតិភូកីឡាគ្រប់បណ្តាប្រទេស ភ្ញៀវជាតិ-អន្តរជាតិ ឱ្យទស្សនាមិនដាក់ភ្នែក ដែលបានបង្ហាញទៅពិភពលោកឱ្យកាន់តែស្គាល់ច្បាស់នូវប្រវត្តិដ៏រុងរឿងថ្កុំថ្កើងរបស់បុព្វបុរសដូនតាខ្មែរនាសម័យអតីតកាល ក៏ដូចជាការអភិវឌ្ឍបច្ចុប្បន្ន និងទៅអនាគត៕



សម្តេចអគ្គមហាសេនាបតីតេជោ
អញ្ជើញប្រគល់ភ្លើងគប់ដល់កីឡាការិនី ខាន់ ចេសា
(ប្រភព៖ www.information.gov.kharticles103781)





សិល្បៈទស្សនីយភាពដ៏អស្ចារ្យ
អបអរពិធីបើកព្រឹត្តិការណ៍ប្រកួតកីឡាស៊ីហ្គេម



ការបាញ់កាំជ្រួចអបអរពិធីបើកព្រឹត្តិការណ៍កីឡាស៊ីហ្គេម
(ប្រភព៖ www.information.gov.kharticles103781)



# ពិធីសម្ពោធស្ពានហាលប្រាសាទអង្គរវត្ត




ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងកាត់ខ្សែបូសម្ពោធស្ពានហាលប្រាសាទអង្គរវត្ត

ស្ពានហាលប្រាសាទអង្គរវត្ត បានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោយពីបានជួសជុលរួច ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងព្រះរាជពិធីជាប្រវត្តិសាស្ត្រនេះ មានការអញ្ជើញចូលរួមដង្ហែព្រះរាជដំណើរ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដោយថ្នាក់ដឹកនាំស្ថាប័នកំពូលរបស់ជាតិព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការតាមក្រសួង-ស្ថាប័ន តំណាងអង្គទូត និងភ្ញៀវជាតិ-អន្តរជាតិជាច្រើនរូបទៀត។



ព្រះមហាក្សត្រ និងថ្នាក់ដឹកនាំជាតិ-អន្តរជាតិ ក្នុងព្រះរាជពិធីសម្ពោធស្ពានហាលប្រាសាទអង្គរវត្ត

ក្នុងឱកាសដ៏មហោឡារិកនេះ ព្រះករុណាព្រះមហាក្សត្រ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃយើង បានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំគ្រប់ស្ថាប័នពាក់ព័ន្ធនិងអ្នកជំនាញជាតិ-អន្តរជាតិដែលបានខិតខំប្រឹងប្រែងក្នុងកិច្ចការស្រាវជ្រាវ និងជួសជុលស្ពានហាលប្រាសាទអង្គរវត្ត នៅពីមុខប្រាសាទអង្គរវត្តដែលជាស្នាព្រះហស្ត និងជានិមិត្តរូបដ៏ខ្ពង់ខ្ពស់នៃមហាវីរក្សត្រសម័យអង្គរ ព្រះបាទសូរ្យវរ្ម័នទី២ ឱ្យរឹងមាំឡើងវិញ ដើម្បីទុកជាកេរដំណែលដ៏មានតម្លៃរបស់វប្បធម៌ខ្មែរនាសម័យអង្គរដ៏រុងរឿង។ ទន្ទឹមនឹងនោះ ព្រះអង្គបានលើកទឹកចិត្តនិងគាំទ្រឱ្យបន្តការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអភិរក្ស និងស្រាវជ្រាវរបស់កម្ពុជា តាមគ្រប់រូបភាព និងគ្រប់ទម្រង់ជាមួយស្ថាប័ននានានៃប្រទេសជប៉ុន ព្រមទាំងជាមួយដៃគូជាតិ និងអន្តរជាតិ។



ព្រះមហាក្សត្រយាងថ្លែងព្រះរាជសុន្ទរកថា ក្នុងព្រះរាជពិធីសម្ពោធស្ពានហាលប្រាសាទអង្គរវត្ត



ព្រះមហាក្សត្រយាងទតស្ពានហាលប្រាសាទអង្គរវត្ត ដែលជួសជុលរួច



ទិដ្ឋភាពស្ពានហាលប្រាសាទអង្គរវត្តដែលបានជួសជុលរួច

ក្នុងអំឡុងពេលជួសជុលស្ពានហាលខាងលើកម្ពុជាក៏បានទទួលការបណ្តុះបណ្តាលពីអ្នកជំនាញជប៉ុន លើកិច្ចការអភិរក្ស និងជួសជុលសំណង់បុរាណ។ បច្ចុប្បន្ន អ្នកជំនាញអាជ្ញាធរជាតិអប្សរាជាច្រើនមានសមត្ថភាពគ្រប់គ្រងការដ្ឋានអភិរក្ស និងជួសជុលប្រាសាទមួយចំនួននៅក្នុងរមណីយដ្ឋានអង្គរបានដោយខ្លួនឯង។

ស្ពមរម្លឹកថាស្ពានហាលប្រាសាទអង្គរវត្តស្ថិតនៅទិសខាងលិចហើយបានចាប់ផ្តើមជួសជុលឡើងវិញកាលពីអំឡុងឆ្នាំ២០១៦ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ានៃប្រទេសជប៉ុន។ បន្ទាប់ពីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ស្ពានបុរាណនេះនឹងប្រើជាផ្លូវចូលទស្សនាប្រាសាទអង្គរវត្ត ហើយស្ពានបណ្តែតទឹកនឹងរក្សាទុកប្រើជាច្រកចេញពីប្រាសាទ៕

# សន្និសីទអន្តររដ្ឋាភិបាលលើកទី៤
## ស្តីពី "រមណីយដ្ឋានអង្គរ-សំបូរព្រៃគុក"




ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី និង មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងលោកជំទាវអគ្គនាយិកាអង្គការយូណេស្កូនៅក្នុងសន្និសីទនាទីក្រុងប៉ារីស៍ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣

"អង្គរ" ដែលជាអតីតរាជធានីនៃចក្រភពខ្មែរដ៏ថ្កុំថ្កើងពីស.វ. ទី៩ដល់១៥ គឺជាបូរីយដ្ឋានបុរាណវិទ្យាដ៏សំខាន់បំផុតមួយនៅអាស៊ីអាគ្នេយ៍ ដែលគ្របដណ្តប់លើផ្ទៃដីជាង៤០០គីឡូម៉ែត្រក្រឡា។ ក្នុងឆ្នាំ១៩៩២ អង្គរត្រូវបានចុះបញ្ជីជា "បេតិកភណ្ឌពិភពលោក"។ មួយឆ្នាំក្រោយមក សន្និសីទអន្តររដ្ឋាភិបាលលើកទី១ បានប្រារព្ធឡើងនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ក្នុងខែតុលា ឆ្នាំ១៩៩៣។ ពេលនោះហើយដែលគណៈកម្មាធិការសម្របសម្រួលអន្តរជាតិសម្រាប់ការពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ឬហៅថ្មីថា "អាយស៊ីស៊ី-អង្គរ" បានចាប់កំណើតឡើង។ អាយស៊ីស៊ីគឺជាយន្តការសម្របសម្រួលអន្តរជាតិដែលចូលរួមពីប្រទេសនិងអង្គការផ្សេងៗសម្រាប់ជួយអភិរក្ស ការពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ។ មកដល់ឆ្នាំ២០១៩ អាយស៊ីស៊ី ក៏បានបញ្ចូលរមណីយដ្ឋានសំបូរព្រៃគុក (ដែលចូលជាបេតិកភណ្ឌពិភពលោកឆ្នាំ២០១៧) ទៅក្នុងគណៈកម្មាធិការនេះដែរដោយហៅថា "អាយស៊ីស៊ីអង្គរ-សំបូរព្រៃគុក"។



ព្រះមហាក្សត្រប្រោសប្រទានឱ្យលោកជំទាវអគ្គនាយិកាអង្គការយូណេស្កូនិងសហការីចូលគាល់

សន្និសីទអន្តររដ្ឋាភិបាលលើកទី៤ ស្តីពី “រមណីយដ្ឋានអង្គរ-សំបូរព្រៃគុក” បានប្រារព្ធឡើងកាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីស្នាក់ការអង្គការយូណេស្កូ នាទីក្រុងប៉ារីស៍ ក្រោមព្រះរាជវត្តមានដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា, លោកជំទាវ Audrey Azoulay អគ្គនាយិកាអង្គការយូណេស្កូ, លោកជំទាវ Rima Abdul Malak រដ្ឋមន្ត្រីក្រសួងវប្បធម៌បារាំង, ឯកឧត្តម Komura Masahiro អនុរដ្ឋមន្ត្រីក្រសួងកិច្ចការបរទេសនៃប្រទេសជប៉ុន, លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈកម្ពុជា, ប្រទេសជាសមាជិកនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ និងបណ្តាប្រទេសជាមិត្តផ្សេងៗទៀត។ សន្និសីទនេះរៀបចំឡើងដើម្បីពិនិត្យលើសមិទ្ធផលអភិវឌ្ឍ និងអភិរក្សរមណីយដ្ឋានអង្គរ-សំបូរព្រៃគុក រយៈពេល៣០ឆ្នាំកន្លងមក ក៏ដូចជាការដាក់ចេញនូវសេចក្តីប្រកាសរួមស្តីពីការបន្តកិច្ចសហប្រតិបត្តិការរយៈពេល១០ឆ្នាំទៅមុខទៀត។



ព្រះមហាក្សត្រ ប្រោសប្រទានឱ្យលោកជំទាវអគ្គនាយិកាអង្គការយូណេស្កូ និងសហការីចូលគាល់




ទន្ទឹមនេះ សន្និសីទបានផ្តល់ទំនុកចិត្តជាថ្មីដល់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ-សំបូរព្រៃគុក ក្រោមការដឹកនាំរបស់សហប្រធានបារាំងនិងជប៉ុន ដោយវាយតម្លៃខ្ពស់បំពោះកំណាត់ត្រានៃកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងក្របខណ្ឌអាយស៊ីស៊ីនារយៈពេល៣០ឆ្នាំកន្លងមក អំពីកិច្ចអភិរក្សនិងអភិវឌ្ឍប្រកបដោយចីរភាពរមណីយដ្ឋានអង្គរនិងតំបន់ជុំវិញ។ សន្និសីទក៏បានកត់សម្គាល់និងវាយតម្លៃខ្ពស់បំពោះកិច្ចខិតខំរបស់សហគមន៍អន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងការលួចគាស់កកាយ, ការជួញដូរសម្បត្តិវប្បធម៌ខុសច្បាប់, បន្តការងារស៊ើបជម្រៅដើម្បីជំរុញការប្រគល់ត្រឡប់មកវិញនូវវត្ថុបុរាណខ្មែរដែលបានបាត់បង់ក្នុងសង្គ្រាមស៊ីវិលកន្លងមក៕

# ការយាងនិវត្តមកកាន់មាតុភូមិ នៃមរតកដូនតា៖

## ពិធីទទួលវត្ថុបុរាណខ្មែរនៅវិមានសន្តិភាព



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អញ្ជើញថ្លែងសុន្ទរកថាក្នុងពិធីទទួលវត្ថុបុរាណខ្មែរនៅវិមានសន្តិភាព

ពិធីទទួលវត្ថុបុរាណខ្មែរដែលបានប្រគល់ជូនព្រះរាជាណាចក្រកម្ពុជាវិញ បានប្រារព្ធឡើងកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ នៅវិមានសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងការអញ្ជើញចូលរួមរបស់សម្តេច ឯកឧត្តម លោកជំទាវ ដែលជាថ្នាក់ដឹកនាំជាន់ខ្ពស់ អង្គទូត មន្ត្រីនៃក្រសួង-ស្ថាប័ន ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិជាច្រើនរូប។

ក្នុងចំណោមវត្ថុបុរាណជាសម្បត្តិវប្បធម៌ដែលទទួលបានមកវិញនេះ មានរូបប្រតិមាព្រហ្មញ្ញសាសនា និងពុទ្ធសាសនាសំខាន់ៗមួយចំនួន ព្រមទាំងគ្រឿងអលង្ការសម័យមុនអង្គរនិងសម័យអង្គរ ជាពិសេសប្រតិមាថ្មធំៗដូចជា ព្រះឥសូរនិងព្រះស្កន្ទ, ព្រះស្កន្ទគង់លើក្ងោក និងព្រះគណេស មានប្រភពដើមមកពីបូជនីយដ្ឋានប្រាសាទកោះកេរជាអតីតរាជធានីនៃអាណាចក្រខ្មែរនៅស.វ.ទី១០គ.ស. ដែលធ្លាប់ជាគោលដៅនៃការលួចទ្រង់ទ្រាយធំអស់ជាច្រើនឆ្នាំនៅអំឡុងសម័យសង្គ្រាមស៊ីវិល។

ការយាងនិវត្តនៃមរតកដូនតាទាំងអស់នេះគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងរវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាតំណាងរាជរដ្ឋាភិបាលកម្ពុជា និងគ្រួសារលោក Douglas Latchford កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២០ ដោយតម្រូវឱ្យប្រគល់ជូនមកកម្ពុជាវិញនូវវត្ថុបុរាណខ្មែរទាំងអស់ដែលគ្រួសារនេះកាន់កាប់រក្សាទុក។ បន្ថែមពីនេះ សម្បត្តិវប្បធម៌ខ្មែរសំខាន់ៗជាច្រើនទៀតដែលរក្សាទុកដោយសារមន្ទីរនានា និងក្នុងសមុច្ច័យឯកជន ដែលខ្លះរឹបអូសបានដោយសមត្ថកិច្ចនិងខ្លះទៀតបានប្រគល់ដោយស្ម័គ្រចិត្ត ក៏បានបញ្ជូនត្រឡប់មកកម្ពុជាវិញជាបន្តបន្ទាប់។

ការទទួលបានវត្ថុបុរាណទាំងនេះមកវិញ គឺតាមរយៈកិច្ចសហការយ៉ាងសកម្មបំផុតពីគ្រប់ភាគីពាក់ព័ន្ធ ទាំងស្ថាប័នរដ្ឋ ឯកជន អ្នកជំនាញជាតិនិងអន្តរជាតិ និងបណ្ដាប្រទេសនានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី និងក្របខ័ណ្ឌនៃអង្គការយូណេស្កូ ជាពិសេសកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ដោយអនុលោមតាមអនុស្សារណៈនៃការយោគយល់គ្នាស្ដីពីការដាក់កម្រិតហាមប្រាមការនាំចូលវត្ថុបុរាណពីប្រទេសកម្ពុជា។ សកម្មភាពទាំងឡាយនេះឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការថែរក្សា ការពារ និងនាំយកមកវិញនូវព្រលឹងដូនតា ដែលបានចាកចេញពីមាតុភូមិក្នុងសម័យសង្គ្រាមកន្លងមកក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងការនាំយកសុខសន្តិភាពជូនកម្ពុជាតាមរយៈនយោបាយឈ្នះឈ្នះរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។



លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា ថ្លែងសុន្ទរកថាក្នុងពិធីទទួលវត្ថុបុរាណខ្មែរនៅវិមានសន្តិភាព



សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អញ្ជើញថ្វាយកម្រងផ្កាដល់រូបប្រតិមា



លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា និងឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ក្នុងពិធីទទួលវត្ថុបុរាណខ្មែរនៅវិមានសន្តិភាព



ព្រះឥសូរនិងព្រះស្កន្ទ ស.វ.ទី១០គ.ស. មកពីប្រាសាទក្របាប់ក្នុងបូជនីយដ្ឋានប្រាសាទកោះកេរ ទទួលបានពីប្រទេសអង់គ្លេសក្នុងឆ្នាំ២០២១

ការវិលត្រឡប់មកវិញនៃព្រលឹងដូនតាខ្មែរនេះគឺមិនត្រឹមតែជាក្តីសោមនស្ស និងមោទនភាពខ្លាំងបំផុតសម្រាប់ប្រជាពលរដ្ឋខ្មែរប៉ុណ្ណោះទេ តែក៏បានចូលរួមចំណែកដ៏ឧត្តុង្គឧត្តមក្នុងការផ្សះផ្សារនិងព្យាបាលរបួសផ្លូវចិត្តរបស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់សង្គ្រាមស៊ីវិលរ៉ាំរ៉ៃនិងរងគ្រោះពីសោកនាដកម្ម និងទារុណកម្មនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហមផងដែរ។



ព្រះស្កន្ទគង់លើក្ងោក ស.វ.ទី១០គ.ស.មកពីប្រាសាទក្របាប់ក្នុងបូជនីយដ្ឋានប្រាសាទកោះកេរ ទទួលបានពីសហរដ្ឋអាមេរិកក្នុងឆ្នាំ២០២១



គណៈប្រតិភូអន្តររដ្ឋាភិបាលនិងអ្នកជំនាញជាន់ខ្ពស់មកពីជុំវិញពិភពលោកចូលរួមនៅក្នុងសន្និសីទអន្តរជាតិស្តីពីកិច្ចការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ប្រារព្ធនៅខេត្តសៀមរាប

ព្រឹត្តិការណ៍ដ៏សំខាន់មួយទៀតដែលបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការតស៊ូមតិជាអន្តរជាតិ ដើម្បីទាមទារវត្ថុបុរាណខ្មែរត្រឡប់មកវិញ គឺការធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទអន្តរជាតិដ៏ធំមួយស្តីពីកិច្ចការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ ក្រោមប្រធានបទ "ការទប់ស្កាត់ការជួញដូរសម្បត្តិវប្បធម៌ខុសច្បាប់៖ទស្សនៈពីអាស៊ាន" ប្រារព្ធនៅខេត្តសៀមរាប កាលពីថ្ងៃទី៥-៨ ខែតុលា ឆ្នាំ២០២២។ កិច្ចប្រជុំនេះ បានប្រមូលផ្តុំថ្នាក់ដឹកនាំអន្តររដ្ឋាភិបាល រួមទាំងអ្នកជំនាញជាន់ខ្ពស់មកពីជុំវិញពិភពលោក ដើម្បីពិភាក្សាលើគោលនយោបាយ និងការអនុវត្តច្បាប់ ព្រមទាំងកិច្ចការពាក់ព័ន្ធនឹងសារមន្ទីរ និងទីផ្សារសិល្បៈ។ ថ្នាក់ដឹកនាំនិងអ្នកជំនាញបម្រុះទាំងអស់ បានរួមគ្នារិះរកដំណោះស្រាយដើម្បីការពារមរតកអតីតកាល និងទាមទារមកវិញនូវសម្បត្តិវប្បធម៌ជាតិរបស់បណ្តាប្រទេសអាស៊ានសម្រាប់កូនចៅជំនាន់ក្រោយ៕



គណៈប្រតិភូនិងអ្នកជំនាញជាន់ខ្ពស់ដែលចូលរួមនៅក្នុងសន្និសីទអន្តរជាតិស្តីពីកិច្ចការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ធ្វើទស្សនកិច្ចនៅតាមបុរាណដ្ឋានសំខាន់ៗក្នុងតំបន់ប្រាសាទកោះកេរ

# អបអរសាទរ
# រមណីយដ្ឋានប្រាសាទកោះកេរ
# ចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក



ប្រាសាទធំជាស្ថាបត្យកម្មសំខាន់មួយក្នុងចំណោមប្រាសាទនានានៅរមណីយដ្ឋានកោះកេរ

រមណីយដ្ឋានប្រាសាទកោះកេរ ដែលក្នុងសិលាចារឹកខ្មែរបុរាណហៅថា “ឆោកគិគ្យរ” មានន័យថា “ស្រះគគីរ” និងឈ្មោះជាភាសាសំស្ក្រឹតថា “លិង្គបុរៈ” មានន័យថា “រាជធានីលិង្គ” គឺជារាជធានីក្នុងសម័យអង្គរចន្លោះឆ្នាំ៩២៨-៩៤៤ នៃគ្រិស្តសករាជ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៤។ រាជធានីនេះត្រូវបានរៀបចំឱ្យក្លាយជាទីក្រុងពិសិដ្ឋ ដោយបានរួមបញ្ចូលរវាងលំហ សណ្ឋានដីភូមិសាស្ត្រ តារាសាស្ត្រ និងសាសនា ព្រមទាំងបានកសាងប្រាសាទ ប្រព័ន្ធធារាសាស្ត្រ និងផ្លូវដែលសរុបមានចំនួន១៦៩បុរាណដ្ឋាន ហើយក្នុងនោះមានប្រាសាទចំនួន៧៦។

អនុលោមតាមគោលនយោបាយនិងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការអភិរក្ស និងអភិវឌ្ឍសម្បត្តិវប្បធម៌ជាតិ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងឆ្នាំ២០១៨ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានដឹកនាំក្រុមការងារអន្តរក្រសួង និងអាជ្ញាធរជាតិព្រះវិហារ រៀបចំឯកសារស្នើទៅអង្គការយូណេស្កូ សុំចុះរមណីយដ្ឋានប្រាសាទកោះកេរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

ឆ្លងកាត់ការប្រជុំពិភាក្សារវាងអ្នកជំនាញជាតិ និងអន្តរជាតិ ព្រមទាំងការចុះសិក្សាវាយតម្លៃនៅលើទីតាំងជាក់ស្តែងជាច្រើនលើក ឯកសារស្នើសុំនេះបានទទួលការអនុម័តពីប្រមុខរាជរដ្ឋាភិបាលដើម្បីដាក់ជូនគណៈកម្មាធិការបេតិកភណ្ឌពិភពលោកពិនិត្យនិងវាយតម្លៃនៅឆ្នាំ២០២១។




លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមប្រជុំ
គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ក្នុងសម័យប្រជុំលើកទី៤៥ នៅទីក្រុងរីយ៉ាដ ប្រទេសអារ៉ាប៊ីសាអូឌីត

នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣ ក្នុងសម័យប្រជុំលើកទី៤៥ នៅទីក្រុងរីយ៉ាដ ប្រទេសអារ៉ាប៊ីសាអូឌីត គណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានសម្រេចជាឯកច្ឆន្ទចុះរមណីយដ្ឋានប្រាសាទកោះកេរ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យសំខាន់ពីរគឺ៖

◈ រមណីយដ្ឋានបុរាណវិទ្យាកោះកេរ គឺជាឧទាហរណ៍ដ៏លេចធ្លោមួយនៃការភប់ប្រសព្វរវាងវប្បធម៌ប្រពៃណីក្នុងស្រុក ជាមួយទស្សនវិជ្ជា និងនិមិត្តរូបសាសនារបស់ឥណ្ឌា ហើយច្នៃបង្កើតចេញទៅជារចនាបថថ្មីមួយ (មានការរៀបចំក្រុង, ស្ថាបត្យកម្ម និងសិល្បៈ) ហៅថា "រចនាបថកោះកេរ" ក្នុងសតវត្សទី១០គ.ស.។ នេះជាការវិវឌ្ឍស្នាដៃសិល្បៈដ៏ប៉ិនប្រសប់និងសំខាន់ ដែលមានឥទ្ធិពលដល់ចក្រភពខ្មែរ និងផ្នែកខ្លះនៃតំបន់អាស៊ីអាគ្នេយ៍។

◆ កោះកេរស្ថាបនាដោយព្រះបាទជ័យវរ្ម័នទី៤ ដែលរួមមានការរៀបចំក្រុង របនាសម្ព័ន្ធប្រាសាទ និងហេដ្ឋារចនាសម្ព័ន្ធនានា គឺជានិមិត្តរូបនៃការរៀបចំក្រុងពិសិដ្ឋដ៏ពិសេសមួយសម្រាប់ជាមណ្ឌលគោរពបូជាព្រះឥសូរ តាមបែបទស្សនៈលោកធាតុហិណ្ឌូ។ អ្វីដែលកាន់តែពិសេសទៀតនោះ គឺការប្រើប្រាស់ផ្ទាំងថ្មធំៗសម្រាប់កសាងប្រាសាទនិងរូបចម្លាក់ គឺជាដំណាក់កាលចាប់ផ្ដើមនៃការសង់ប្រាសាទថ្មនៅទូទាំងបក្រភពខ្មែរជាប្រើនសតវត្សរ៍នាសម័យក្រោយៗទៀត។



សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត និង លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ព្រមទាំងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីអបអរសាទរមណីយដ្ឋានប្រាសាទកោះកេរចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅពហុកីឡដ្ឋានជាតិអូឡាំពិក





ថ្នាក់ដឹកនាំ មន្ត្រីរាជការ សិស្សានុសិស្ស និងប្រជាពលរដ្ឋ ចូលរួមអបអរសាទរមណីយដ្ឋានប្រាសាទកោះកេរចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកយ៉ាងច្រើនកុះករនៅពហុកីឡដ្ឋានជាតិអូឡាំពិក

ដើម្បីអបអរសាទរការទទួលស្គាល់ជាសកល បំពោះស្នាដៃបុព្វបុរសខ្មែរដែលបានបន្សល់ទុករាប់ពាន់ឆ្នាំមកនេះ រាជរដ្ឋាភិបាលបានអំពាវនាវឱ្យគ្រប់ក្រសួង-ស្ថាប័ន អង្គភាពរដ្ឋបាលរាជធានី-ខេត្ត វត្តអារាម សាលារៀន និងសាលាបុណ្យ ព្រមទាំងទីប្រជុំជន សហគមន៍ រៀបចំវាយគង ទូងស្គរ ទះប៉ោត និងគោះត្រដោក តាមគ្រប់មធ្យោបាយដែលខ្លួនមាននៅវេលាម៉ោង៧:០០នាទីព្រឹក នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣។ មិនតែប៉ុណ្ណោះ នាថ្ងៃដដែលនោះ រាជរដ្ឋាភិបាលក៏បានរៀបចំពិធីអបអរសាទរដ៏មហោឡារិកអធិកអធម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ព្រមទាំងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន នៅពហុកីឡដ្ឋានជាតិអូឡាំពិក ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិស្សានុសិស្ស និងមហាជនសរុបប្រមាណប្រាំបួនម៉ឺននាក់៕



ទិដ្ឋភាពព្រះសង្ឃទូងស្គរអបអររមណីយដ្ឋានប្រាសាទកោះកេរបុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក





សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និង លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត អញ្ជើញប្រារព្ធពិធីបួងសួង និងអបអររមណីយដ្ឋានប្រាសាទកោះកេរបុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅមុខប្រាសាទធំក្នុងរមណីយដ្ឋានប្រាសាទកោះកេរ

# អបអរសាទរទីក្រុងបាត់ដំបងចុះក្នុងបញ្ជី “បណ្ដាញទីក្រុងច្នៃប្រតិដ្ឋអង្គការយូណេស្កូ”




បណ្ណផ្សព្វផ្សាយអបអរទីក្រុងបាត់ដំបងចុះក្នុងបញ្ជីបណ្ដាញទីក្រុងច្នៃប្រតិដ្ឋ

បាត់ដំបង គឺជាខេត្តស្ថិតនៅភាគពាយ័ព្យប្រទេស ដែលមានឈ្មោះល្បីផ្នែកស្រូវ-អង្ករ ផ្លែឈើ និងម្ហូបអាហារ។ កេរ្តិ៍ឈ្មោះទាំងនេះគេតែងឃើញរៀបរាប់ក្នុងបទនិពន្ធផ្សេងៗជាពិសេសនៅក្នុងទំនុកច្រៀងតាអំឡុងទសវត្សរ៍ទី៦០ ហើយបច្ចុប្បន្នក៏បានក្លាយជាផ្នែកមួយយ៉ាងសំខាន់នៃការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យធ្វើដំណើរទៅទស្សនាកម្សាន្ត និងទទួលទានម្ហូបចំណីនៅបាត់ដំបង។ ដោយមើលឃើញពីសក្ដានុពលនិងលក្ខណៈសម្បត្តិលេចធ្លោដូច្នេះហើយ ទើបក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សហការជាមួយក្រសួងទេសចរណ៍ អាជ្ញាធរ និងម្ចាស់អាហារដ្ឋានក្រុងបាត់ដំបង និងអង្គការយូណេស្កូការិយាល័យភ្នំពេញ រៀបចំឯកសារស្នើចុះទីក្រុងបាត់ដំបងក្នុងបញ្ជីទីក្រុងច្នៃប្រតិដ្ឋផ្នែកម្ហូបអាហាររបស់អង្គការយូណេស្កូ។ ជាលទ្ធផលកាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ អង្គការយូណេស្កូបានប្រកាសទទួលស្គាល់និងចុះក្រុងបាត់ដំបងក្នុងបញ្ជី “បណ្ដាញទីក្រុងច្នៃប្រតិដ្ឋផ្នែកម្ហូបអាហារ” (Creative City Network of Gastronomy)។ ជោគជ័យនេះ គឺជាមោទនភាពជាតិថ្មីបន្ថែមទៀតរបស់កម្ពុជា ដ្បិតបាត់ដំបងជាទីក្រុងទី១របស់ព្រះរាជាណាចក្រកម្ពុជាដែលជាប់ក្នុងបញ្ជីទីក្រុងច្នៃប្រតិដ្ឋរបស់អង្គការយូណេស្កូ។



ឯកឧត្តម សុខ លូ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបងអញ្ជើញជាអធិបតីក្នុងពិព័រណ៍ម្ហូបអាហាររៀបចំនៅក្រុងបាត់ដំបង



អាហារខេត្តបាត់ដំបង



អាហារខេត្តបាត់ដំបង

ដូចជ្រាបស្រាប់ថា មុខម្ហូបល្បីៗប្រចាំបាត់ដំបងមានច្រើនណាស់ដូចជា ណែមត្រី, ហហ្មុក, ប្រហុកខ្ទិះ, ក្រឡាន, សង្ខ្យាក់, បុកល្ហុង, បុកកន្ទុយហែស, សំបកណែម, មីគាវ, មីកន្តាំង, មីកូឡា, នំបញ្ចុកទឹកអំព្រឹក និងទឹកគ្រឿងបាត់ដំបង... សុទ្ធសឹងតែជាមុខម្ហូបពេញនិយមរបស់អ្នកបាត់ដំបង ហើយភ្ញៀវទេសចរដែលទៅលេងបាត់ដំបងតែងនិយមទទួលទានពុំដែលខាន។ លើសពីនេះ តាមរយៈការរៀបចំមហោស្រពតាំងបង្ហាញម្ហូបអាហារប្រចាំតំបន់ដែលរៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គេសង្កេតឃើញប្រតិភូខេត្តបាត់ដំបង តែងនាំយកមកបង្ហាញនូវម្ហូបនិងបង្អែមសំខាន់ៗប្រចាំខេត្តដូចជា បបរគ្នោត, កក្កូរគ្នោត, មៀងក្រូប, សម្លម្ជូរដើមបេក, បង្អែមបេកខ្ទិះ, ផ្អកត្រីប្រៃ, សម្លម្ជូរខ្ទិះ និងញាំក្រូបថ្លុងជាដើម។ មុខម្ហូបនិងបង្អែមបាត់ដំបងទាំងអស់នោះ តែងទទួលបានការគាំទ្រ និងកោតសរសើរទាំងរសជាតិ និងអត្តសញ្ញាណតំបន់ ពីគណៈកម្មការដាក់ពិន្ទុនិងថ្នាក់ដឹកនាំជានិច្ច។ មិនតែប៉ុណ្ណោះ ក្នុងឱកាសឆ្លងឆ្នាំសកល២០២៣ ចូល២០២៤ថ្មីៗនេះ រដ្ឋបាលខេត្តបាត់ដំបងក៏បានរៀបចំពិព័រណ៍តាំងបង្ហាញមុខម្ហូបល្បីៗប្រចាំខេត្តផងដែរ។ ដូច្នេះការក្លាយខ្លួនជាសមាជិកបណ្ដាញទីក្រុងច្នៃប្រតិដ្ឋរបស់អង្គការយូណេស្កូនេះនឹងជួយលើកស្ទួយនិងផ្សព្វផ្សាយកេរ្តិ៍ឈ្មោះខេត្តបាត់ដំបងឱ្យកាន់តែល្បីខ្ទរខ្ទារ ដែលជាសក្ដានុពលស្រូបទាញទេសចរជាតិ និងអន្តរជាតិ ហើយនាំមកនូវបំណូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ។



សូមបញ្ជាក់ថា បណ្ដាញទីក្រុងច្នៃប្រតិដ្ឋរបស់អង្គការយូណេស្កូ ឬ UNESCO Creative Cities Network (UCCN) បានបង្កើតឡើងតាំងពីឆ្នាំ២០០៤ ដោយបែងចែកជា៧ប្រភេទគឺៈ សិប្បកម្មនិងសិល្បៈប្រជាប្រិយ (Crafts and Folk Art), សិល្បៈនៃប្រព័ន្ធផ្សព្វផ្សាយ (Media Arts), ភាពយន្ត (Film), ការរចនា (Design), ម្ហូបអាហារ (Gastronomy), អក្សរសិល្ប៍និងតន្ត្រី (Literature and Music)។ មកដល់បច្ចុប្បន្ន សមាជិកបណ្ដាញទីក្រុងច្នៃប្រតិដ្ឋនេះមានចំនួន៣៥០ទីក្រុង មកពីប្រទេសជាងមួយរយ ដែលក្នុងនោះរួមទាំងកម្ពុជាផង។



អាហារខេត្តបាត់ដំបង

# ជំនាញវិជ្ជាជីវៈដូនតា៖ ថ្នាលបណ្ដុះវប្បធម៌ជាតិ

ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូនតា គឺជាកម្មវិធីគោលនយោបាយអាទិភាពមួយនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល សំដៅយកចិត្តទុកដាក់ដល់ការអភិរក្ស និងលើកស្ទួយ ព្រមទាំងផ្ទេរបំណេះជំនាញសិប្បកម្ម និងសិល្បៈប្រពៃណីដល់យុវជនពិសេសយុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស។ ផ្អែកលើគោលនយោបាយនេះ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានតួនាទី និងភារកិច្ចដឹកនាំការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូនតាដល់យុវជនគោលដៅ ប្រកបដោយប្រសិទ្ធភាព និងគុណភាព អនុលោមតាមអនុក្រឹត្យលេខ៣២៩អនក្រ.បក ស្តីពីការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដែលរាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការជាមួយនឹងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។




សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធី នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ (ប្រភព៖ https://pressocm.gov.kh/archives/87096)




បណ្ណផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូនតា របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ



ថ្នាក់ដឹកនាំ និងមន្ត្រីរាជការចូលរួមក្នុងពិធីប្រកាសតាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគារ រ៉េស៊ីដង់សុខាភ្នំពេញ (ប្រភព៖ https://pressocm.gov.kh/archives/87096)



ថ្នាក់រៀនជំនាញបម្លាក់ស្បែកនៅក្រុងសៀមរាប

ឆ្លើយតបនឹងទំនួលខុសត្រូវខាងលើ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានកំណត់គោលដៅនិងទីតាំងបណ្តុះបណ្តាលក្នុងដំណាក់កាលដំបូងចំនួន១៣ទីតាំងក្នុង៨រាជធានី-ខេត្ត ចាប់ពីខែកុម្ភៈឆ្នាំ២០២៤ តទៅ។ ជំនាញដែលនឹងបណ្តុះបណ្តាលនោះរួមមាន ទូកស្នាប់, បម្លាក់ប្រាក់ស្ពាន់, បម្លាក់ស្បែក, បម្លាក់ថ្ម, តម្បាញក្រមាត្រុំ, ស្មូនឆ្នាំង,ការផលិតឧបករណ៍ភ្លេង, តម្បាញសូត្រ, គំនូរពណ៌, គំនូរបុរាណ និងបម្លាក់ស្មិត។ ចំពោះសិស្សដែលមកពីគ្រួសារក្រីក្រដែលមានបណ្ណសមធម៌ និងគ្រួសារងាយរងហានិភ័យ ដែលមានបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ នឹងទទួលបានប្រាក់ឧបត្ថម្ភចំនួន២៨ម៉ឺនរៀលក្នុងមួយខែ ដោយត្រូវបំពេញលក្ខខណ្ឌសិក្សាឱ្យបានត្រឹមត្រូវ។



ស្តូនផ្ទាំងនៅខេត្តរតនគិរី



ថ្នាក់រៀនជំនាញចម្លាក់ថ្ម នៅប្លុំអាគសេនធ័រ ក្រុងសៀមរាប

គួររម្លឹកថា កាលពីដើមឆ្នាំ២០២៣ កន្លងទៅ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលកាលនោះជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានស្នើឱ្យមានការសិក្សាដើម្បីផ្តល់លទ្ធភាពការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនក្រីក្រជាង១,៥លាននាក់ នៅទូទាំងប្រទេស ហើយក្នុងនោះក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានទទួលចំនួន២% ទៅ៤% ដែលស្មើនឹង៣ម៉ឺនទៅ៦ម៉ឺននាក់ សម្រាប់ការបណ្តុះបណ្តាលយុវជនលើជំនាញវិជ្ជាជីវៈជូនតា។



ថ្នាក់រៀនជំនាញចម្លាក់ប្រាក់-ស្ពាន់ នៅកំពង់ហ្លួង ខេត្តកណ្តាល

កម្មវិធីនេះ នឹងផ្តល់ឱកាសស្មើៗគ្នាដល់យុវជនក្នុងការទទួលបានការអភិវឌ្ឍបំណោះជំនាញ និងឱកាសការងារកាន់តែល្អប្រសើរសម្រាប់បង្កើនប្រាក់ចំណូល និងជីវភាពរស់នៅទៅថ្ងៃអនាគត។

# ព្រឹត្តិការណ៍ "រម្លឹកគុណអង្គរ"
## បណ្ដុះស្មារតីយុវជនឱ្យស្រឡាញ់មរតកវប្បធម៌ជាតិ



សម្ដេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និង លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត អញ្ជើញជាអធិបតីក្នុងពិធីបួងសួងនិងរាប់បាត្របើកព្រឹត្តិការណ៍រម្លឹកគុណអង្គរនៅស្ពានហាលប្រាសាទអង្គរវត្ត នាព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣





ក្បួនដង្ហែរបស់សិស្សានុសិស្សនិងក្រុមសិល្បៈ អបអរពិធីបុណ្យរម្លឹកគុណអង្គរ

ព្រឹត្តិការណ៍ "រម្លឹកគុណអង្គរ" រៀបចំដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងអាជ្ញាធរជាតិអប្សរា ដែលប្រារព្ធឡើងក្នុងគោលបំណងអបអរខួប៣១ឆ្នាំនៃការចុះរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ព្រមទាំងរម្លឹកដល់ព្រះគុណព្រះមហាក្សត្រគ្រប់ជំនាន់ និងបុព្វការីជនដែលបានកសាង និងឃុំគ្រងថែរក្សាតំបន់រមណីយអង្គរដែលជាសម្បត្តិបេតិកភណ្ឌពិភពលោកមិនអាចកាត់ថ្លៃបាន។ ព្រឹត្តិការណ៍នេះបានបណ្ដុះស្មារតីយុវជនឱ្យគោរពស្រឡាញ់ ចូលរួមថែរក្សា ការពារ និងលើកតម្លៃមរតកវប្បធម៌ តាមរយៈ



ព្រះសង្ឃនិមន្តចូលរួមពិធីបួងសួងនិងរាប់បាត្រ



ទិដ្ឋភាពពិធីបួងសួងនិងរាប់បាត្រនៅខាងមុខស្ពានហាលប្រាសាទអង្គរវត្ត



សិស្សានុសិស្សទស្សនកិច្ចសិក្សានៅតាមប្រាសាទនិងសារមន្ទីរ





ការរៀបចំក្បួនព្យុហយាត្រាដោយមានសិស្សានុសិស្សចូលរួមសរុប១២៥០នាក់។ បន្ថែមពីនេះ សិស្សតាមបណ្ដាសាលាជាច្រើនត្រូវបានលើកទឹកចិត្ត និងសម្របសម្រួលឱ្យចុះសិក្សានៅតាមការដ្ឋានជួសជុលប្រាសាទនានា សារមន្ទីរ និងពិព័រណ៍សមិទ្ធផលនៃអាជ្ញាធរជាតិអប្សរា ព្រមទាំងចូលរួមទស្សនាកម្មវិធីទស្សនីយភាពសិល្បៈចម្រុះនានានៅក្នុងរមណីយដ្ឋានអង្គរ។ ព្រឹត្តិការណ៍រម្លឹកគុណអង្គរមានរយៈពេល១០ថ្ងៃ ដោយចាប់បើកពីថ្ងៃទី៧ ដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣ ហើយមានអ្នកចូលរួមប្រមាណប្រាំបីម៉ឺននាក់។

“រាត្រីបងចាំ” ជាព្រឹត្តិការណ៍វប្បធម៌មួយទៀតរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលរៀបចំឡើង ដើម្បីអបអរព្រឹត្តិការណ៍ខាងលើផង ព្រមទាំងអបអរខួបនៃការដាក់បញ្ចូលមរតកវប្បធម៌អរូបីកម្ពុជាក្នុងបញ្ជីអង្គការយូណេស្កូរួមមាន របាំព្រះរាជទ្រព្យ, ល្ខោនស្រមោលស្បែកធំ, ល្បែងទាញព្រ័ត្រ, ចាប៉ីដងវែង, ល្ខោនខោល និងគុនល្បុក្កតោ។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះក៏ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិតាមរយៈវិស័យទេសចរណ៍នៅតំបន់សៀមរាប-អង្គរ ស្របតាមយុទ្ធសាស្ត្ររាជរដ្ឋាភិបាលដែលបានដាក់ចេញគឺ “ទស្សនាសៀមរាបឆ្នាំ២០២៤” និងជាចលករបំផុសស្មារតីសាធារណជនជាតិ-អន្តរជាតិ ពិសេសយុវជនឱ្យយល់ដឹង ស្រឡាញ់ និងចូលរួមកាន់តែសកម្មថែមទៀតក្នុងការផ្សព្វផ្សាយ ថែរក្សា ការពារ និងលើកតម្លៃមរតកវប្បធម៌ជាតិក្នុងសម័យសាកលភាវូបនីយកម្មនិងបច្ចេកវិទ្យាទំនើប។


ការសម្តែងសិល្បៈក្នុងរាត្រីបងចាំ
អបអរបុណ្យរម្លឹកគុណអង្គរ


ទស្សនិកជនយ៉ាងច្រើនកុះករមកទស្សនា
ការសម្តែងសិល្បៈទស្សនីយភាពនៅលានជល់ដំរី

ព្រឹត្តការណ៍ដ៏មហោឡារិកនេះរៀបចំនៅរាត្រីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ នៅទីលានជល់ដំរី ដោយមានសម្តែងសិល្បៈទស្សនីយភាពចម្រុះ ហើយទទួលបានការសាទរ និងចូលរួមទស្សនាពីសារធារណជន យុវជន និងសិស្សានុសិស្សយ៉ាងច្រើនកុះករ៕

# ការអភិរក្សនិងផ្សព្វផ្សាយ
# មរតកវប្បធម៌អរូបី

# “សរសេរបំណាន អានបំណាប់ ចាប់យកបំណេះ”៖ ពិព័រណ៍សៀវភៅកម្ពុជា លើកទី១០ ឆ្នាំ២០២៣

ពិព័រណ៍សៀវភៅកម្ពុជាលើកទី១០ បានរៀបចំឡើងកាលពីថ្ងៃទី១៤ ដល់ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ នៅក្នុងផ្លាស្ទនប្បារនៃមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ ក្រោមប្រធានបទ “សរសេរបំណាន អានបំណាប់ ចាប់យកបំណេះ” ។ ពិធីសម្ពោធបើកពិព័រណ៍ថ្នាក់ជាតិនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំ, មន្ត្រីរាជការតាមក្រសួងស្ថាប័ននានា ព្រមទាំងព្រះសង្ឃ, ពុទ្ធិកសមាគមកម្ពុជរដ្ឋ, បណ្ណារក្ស, មិត្តកាយឫទ្ធិនារីអាស៊ីប៉ាស៊ីហ្វិក, កងយោធពលខេមរភូមិន្ទ, នាយក, នាយិកា, សាស្ត្រាចារ្យអនុវិទ្យាល័យនិងវិទ្យាល័យមកពីខេត្តកណ្តាល និងអង្គការ-សមាគមសរុបប្រមាណ ២០០អង្គ/នាក់។



ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន អញ្ជើញកាត់ខ្សែបូបើកពិព័រណ៍សៀវភៅ



ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន អញ្ជើញទស្សនាតាមតូបលក់សៀវភៅ




លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា ថតរូបអនុស្សាវរីយ៍ជាមួយយុវជន



ឯកឧត្តម ខៀវ កាញារីទ្ធ អញ្ជើញចូលរួមក្នុងពិព័រណ៍សៀវភៅ



សកម្មភាពសម្តែងសិល្បៈក្នុងព្រឹត្តិការណ៍ពិព័រណ៍សៀវភៅ

គោលបំណងនៃការរៀបចំពិព័រណ៍សៀវភៅកម្ពុជានេះ គឺដើម្បីអភិរក្សនិងអភិវឌ្ឍវិស័យអក្សរសាស្ត្រ ដែលជាកេរដំណែលបុព្វបុរសខ្មែរឱ្យកាន់តែខ្ពង់ខ្ពស់, ជំរុញនិងលើកកម្ពស់ការអានតែងនិពន្ធនិងបោះពុម្ពផ្សាយនៅកម្ពុជា, ផ្សព្វផ្សាយ និងបំផុសទឹកចិត្តប្រជាពលរដ្ឋ ពិសេសយុវជនឱ្យស្រឡាញ់និងយល់ដឹងនូវគុណតម្លៃនៃអក្សរសាស្ត្រជាតិ ហើយចូលរួមអាននិងសរសេរឱ្យបានកាន់តែច្រើនឡើង, ជំរុញឱ្យប្រជាជនខ្មែរមានទម្លាប់អានសៀវភៅ ហើយជាសារមួយបញ្ជូនទៅដល់យុវជន ឱ្យស្គាល់ពីគុណតម្លៃនៃការអាន ដើម្បីអភិវឌ្ឍបំណោះដឹងនិងបង្កើនគំនិតសម្រាប់ការសិក្សានិងការងារ ព្រមទាំងជួយគាំទ្រស្វែងរកទីផ្សារក្នុងការលក់និងទិញនៃឧស្សាហកម្មសៀវភៅនៅក្នុងប្រទេស និងទីផ្សារអន្តរជាតិ។



សកម្មភាពសម្តែងសិល្បៈ
ក្នុងព្រឹត្តិការណ៍ពិព័រណ៍សៀវភៅ



កុមារ យុវជន ប្រជាពលរដ្ឋ និងព្រះសង្ឃចូលរួមក្នុងព្រឹត្តិការណ៍សៀវភៅ

សកម្មភាពសំខាន់ៗនៃព្រឹត្តិការណ៍ពិព័រណ៍សៀវភៅកម្ពុជាលើកទី១០ រួមមានជួបជាការដាក់តាំង និងលក់សៀវភៅដែលចូលរួមពីអ្នកនិពន្ធ គ្រឹះស្ថានបោះពុម្ពផ្សាយ និងបណ្ណាគារនានា, ការធ្វើបទបង្ហាញទាក់ទងទៅនឹងអក្សរសាស្ត្រ អក្សរសិល្ប៍ខ្មែរ និងវិទ្យាសាស្ត្រ, ការនិពន្ធសៀវភៅនិងការអភិវឌ្ឍជំនាញអាន, ជំនួបពិភាក្សា និងការទទួលយកបទពិសោធពីអ្នកនិពន្ធល្បីៗ ព្រមទាំងកម្មវិធីអានរឿង និងល្បែងសិក្សាសម្រាប់កុមារ, ការប្រគំតន្ត្រីនិងសំណួរបម្លើយចាប់យករង្វាន់ផ្សេងៗ។

ព្រឹត្តិការណ៍ពិព័រណ៍សៀវភៅកម្ពុជាលើកទី១០ មានតូបលក់សៀវភៅចំនួន២៤៨ ដោយមានការចូលរួមឧបត្ថម្ភគាំទ្រពីក្រុមហ៊ុននិងវិស័យឯកជនចំនួន៨, ដៃគូសហការចំនួន១២, យុវជនស្ម័គ្រចិត្តចំនួន២០០នាក់ និងអាជ្ញាធររដ្ឋបាលរាជធានីភ្នំពេញ, រដ្ឋបាលខណ្ឌចំការមន, មន្ទីរសុខាភិបាលរាជធានីភ្នំពេញ...។ ពិព័រណ៍សៀវភៅនេះ មានសាធារណជនចូលរួមទស្សនាចំនួន២០២.៩៤០នាក់ គឺមានការកើនឡើង៨៥% បើធៀបទៅនឹងពិព័រណ៍សៀវភៅឆ្នាំ២០២២។ ផ្អែកលើតួលេខនេះឆ្លុះបញ្ចាំងឱ្យឃើញថា ប្រជាជនកម្ពុជាកាន់តែមានការចាប់អារម្មណ៍មកលើវិស័យការអាននិងជួយលើកស្ទួយការបោះពុម្ពផ្សាយក្នុងប្រទេសកម្ពុជា។ តាមរយៈព្រឹត្តិការណ៍ពិព័រណ៍សៀវភៅពីមួយឆ្នាំទៅមួយឆ្នាំ គឺមានការចូលរួមពីមហាជនកាន់តែច្រើនឡើងៗ ក៏ព្រោះតែការស្រឡាញ់និងចូលចិត្តអានសៀវភៅដែលលើកកម្ពស់ការយល់ដឹងកាន់តែទូលំទូលាយអំពីការអាននិងការសរសេរ, លើកតម្កើងអក្សរសាស្ត្រជាតិ ព្រមទាំងជួយជំរុញការអាន និងការសរសេរឱ្យមានសន្ទុះទៅមុខថែមទៀត ព្រោះការអានសៀវភៅនិងការសិក្សាធ្វើឱ្យយើងទទួលបាននូវសម្បទា៣ គឺវិជ្ជាសម្បទា បំណិនសម្បទា និងបរិយាសម្បទា៕

# "សំណេរអង្គរ"៖

# ការប្រឡងសរសេរតាមអានថ្នាក់ជាតិជាសាធារណៈ

"សំណេរអង្គរ" ជាព្រឹត្តិការណ៍ប្រឡងសរសេរតាមអានថ្នាក់ជាតិជាសាធារណៈ ដែលផ្ដួចផ្ដើមឡើងដោយក្រុមស្ថាបនិក តំណាងដោយលោក លឹម ប៊ុនហុក និងការចូលរួមសហការពី ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងទេសចរណ៍, អាជ្ញាធរ, សាកលវិទ្យាល័យអង្គរ និងភាគីពាក់ព័ន្ធ ក្នុងគោលបំណងលើកកម្ពស់ និងជំរុញទឹកចិត្តប្រជាពលរដ្ឋខ្មែរឱ្យស្រឡាញ់អក្សរសាស្ត្រជាតិ។ ព្រឹត្តិការណ៍នេះក៏បានផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ ដោយផ្ដោតសំខាន់លើការអភិវឌ្ឍមូលធនមនុស្ស ដែលជាធនធានសំខាន់ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច ដើម្បីឈានឆ្ពោះនិងសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងមហិច្ឆតាក្លាយជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។




លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា អញ្ជើញជាអធិបតីក្នុងព្រឹត្តិការណ៍ "សំណេរអង្គរ"

កម្មវិធី"សំណេរអង្គរ" លើកទី១ បានប្រារព្ធឡើងនៅលើស្ពានហាលខាងលិចប្រាសាទអង្គរវត្ត នាព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០២៤ ក្រោមអធិបតីភាពលោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយមានបេក្ខជនទាំងព្រះសង្ឃនិងគ្រហស្ថជាង៧០០អង្គ/នាក់ ចូលរួមប្រឡងសរសេរតាមអាននូវអត្ថបទក្រោមចំណងជើងថា "អង្គរ អាណាចក្រនៃអរិយធម៌ខ្មែរ" ហើយបេក្ខជន៣រូបទទួលបានជ័យលាភីគឺ៖ បេក្ខជន ចេង វតនា ទទួលបានជ័យលាភីលេខ១, បេក្ខជន វ៉ែន វីដា ទទួលបានជ័យលាភីលេខ២ និងបេក្ខនារី យ៉ោប សុឃាក់ ទទួលបានជ័យលាភីលេខ៣។







លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អញ្ជើញប្រគល់រង្វាន់លើកទឹកចិត្តដល់បេក្ខជន បេង រតនា ដែលឈ្នះជ័យលាភីលេខ១

ព្រឹត្តិការណ៍នេះបានទាក់ទាញការចាប់អារម្មណ៍ខ្លាំងពីសាធារណជន ជាពិសេសយុវជនដែលជាកម្លាំងចលករចូលរួមក្នុងការលើកកម្ពស់នូវបំណោះដឹងទូទៅ អត្តសញ្ញាណជាតិ សាមគ្គីភាព ក៏ដូចជាលើកតម្កើងអក្សរសាស្ត្រជាតិឱ្យកាន់តែផុលផុសបន្ថែមទៀតដោយសង្ឃឹមថានឹងក្លាយជាទិវាជាតិប្រចាំឆ្នាំនាពេលអនាគត៕

ព្រះសង្ឃនិងគ្រហស្ថចូលរួមប្រឡងសរសេរតាមអាន "សំណេរអង្គរ"



# ការគិតគូររបស់កម្ពុជា
## ក្នុងការចូលរួមអភិវឌ្ឍវិស័យសិប្បកម្មនិងវប្បធម៌-សិល្បៈ
## នៅអាស៊ីអាគ្នេយ៍ក្រោយការរីករាលដាលនៃជំងឺកូវីដ-១៩

ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងតំបន់ និងពិភពលោកបានជះឥទ្ធិពលអាក្រក់បំផុតដល់ជីវភាពរស់នៅរបស់ប្រជាជន និងសេដ្ឋកិច្ចសង្គម ដែលជំរុញឱ្យអាស៊ានដើរតួនាទីឈានមុខនិងបន្ទាន់ដើម្បីស្វែងរកដំណោះស្រាយ ព្រមទាំងរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយឆ្លើយតបទៅនឹងវិបត្តិដ៏គ្រោះថ្នាក់ខាងលើ។ មិនតែប៉ុណ្ណោះ វាក៏តម្រូវឱ្យរដ្ឋាភិបាល និងប្រទេសទាំងអស់រួបរួមគ្នាទប់ទល់និងសម្រាលផលប៉ះពាល់នេះ។ ជំងឺកូវីដ-១៩ បានបណ្ដាលឱ្យបាត់បង់ជីវិត និងប៉ះពាល់សុខភាពយ៉ាងធ្ងន់ធ្ងរ។ លើសពីនេះទៅទៀតបានធ្វើឱ្យតារា សិល្បករ ពិសេសសិប្បករបាត់បង់ប្រាក់ចំណូល ដ្បិតរោងភាពយន្ត, រោងល្ខោន, សារមន្ទីរ, វិចិត្រសាល, សិប្បកម្ម។ល។ ត្រូវបិទទ្វារ និងផ្អាកលែងដំណើរការ។ ការជួបជុំ និងការធ្វើដំណើរទាំងក្នុងស្រុក និងឆ្លងប្រទេសក៏ត្រូវហាមឃាត់។



លោកជំទាវ ប៉ែន មុនីមករា រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អញ្ជើញថ្លែងសុន្ទរកថាក្នុងពិធីបើកសិក្ខាសាលា



គណៈអធិបតីនិងសិក្ខាកាមចូលរួមក្នុងសិក្ខាសាលា



ទិដ្ឋភាពក្នុងសិក្ខាសាលា

កិច្ចពិភាក្សា
ក្នុងសិក្ខាសាលា



ចាប់តាំងពីការផ្ទុះជំងឺកូវីដ-១៩នៅចុងឆ្នាំ២០១៩មក រដ្ឋសមាជិកអាស៊ានទាំងអស់ បានរួបរួមកម្លាំងគ្នាចាត់វិធានការរារាំងការរីករាលដាលនៃជំងឺដ៏កាចសាហាវមួយនេះ ដើម្បីនាំមកនូវការអភិវឌ្ឍប្រកបដោយចីរភាព បង្កើតឱ្យមានភាពធន់ និងភាពរីកចម្រើនក្នុងវិស័យវប្បធម៌ និងសិល្បៈ នៅក្រោយការរាតត្បាតនៃជំងឺសកលខាងលើ។ ជាក់ស្តែងនៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកវប្បធម៌និងសិល្បៈ ឬហៅថា AMCA (ASEAN Ministers Responsible for Culture and Arts) លើកទី៩ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ បានលើកឡើងថា ដើម្បីធានាថាប្រជាជាតិអាស៊ានមានសុវត្ថិភាពនិងស្ថិរភាពសង្គម ព្រមទាំងការអភិវឌ្ឍសេដ្ឋកិច្ច គឺត្រូវរៀបចំសកម្មភាពវប្បធម៌ជាបន្តបន្ទាប់ក្រោមប្រធានបទ “ផលប៉ះពាល់នៃជំងឺកូវីដ-១៩ក្នុងវិស័យវប្បធម៌ និងមធ្យោបាយឆ្ពោះទៅមុខសម្រាប់វិស័យវប្បធម៌និងសិល្បៈ” ដោយការលើកស្ទួយមរតកវប្បធម៌ទាំងរូបីនិងអរូបីតាមរយៈសកម្មភាពសិល្បៈទាំងផ្ទាល់និងមធ្យោបាយអេឡិចត្រូនិចផ្សេងៗ។

ក្នុងន័យនេះហើយដែលកម្ពុជាជារដ្ឋសមាជិក តាមរយៈសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានឱកាសនិងកិត្តិយសធ្វើជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលាស្តីពី “ការអភិវឌ្ឍវិស័យវប្បធម៌ និងសិល្បៈនៅអាស៊ីអាគ្នេយ៍ ពិសេសផ្នែកសិប្បកម្មក្រោយការឆ្លងរាតត្បាតជំងឺកូវីដ-១៩” ដើម្បីស្វែងរកយុទ្ធសាស្ត្រ មធ្យោបាយ និងអនុសាសន៍ក្នុងការកែលម្អ និងបង្កើនប្រាក់ចំណូលក្នុងវិស័យវប្បធម៌ និងសិល្បៈ ដើម្បីជួយឱ្យប្រជាជននៅក្នុងតំបន់អាស៊ានកាន់តែមានភាពច្នៃប្រតិដ្ឋ ហើយបង្កើតភាពធន់ ដែលអាចឆ្លើយតបបានកាន់តែប្រសើរចំពោះបញ្ហាផ្សេងៗ ក៏ដូចជាបង្កើតវប្បធម៌នៃភាពជាសហគ្រិននៅក្នុងតំបន់អាស៊ានជាពិសេសផ្នែកសិល្បៈហត្ថកម្មបន្ទាប់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ ។







ទស្សនកិច្ចនៅតាមសហគមន៍សិប្បកម្មប្រពៃណីនៅខេត្តកណ្ដាលនិងខេត្តកំពង់ឆ្នាំង

សិក្ខាសាលាត្រូវបានរៀបចំនៅក្នុងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ រយៈពេល ៣ថ្ងៃ គឺពីថ្ងៃទី៦ ដល់ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមអធិបតីភាពលោកជំទាវ ប៉ែន មុនីមករា រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយមានការចូលរួមពីថ្នាក់ដឹកនាំសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាស្ត្រាចារ្យ, សិល្បករ, សិប្បករ, រដ្ឋបាល, អ្នកបង្កើតគោលនយោបាយ និងអ្នកជំនាញវប្បធម៌ មកពីបណ្ដាប្រទេសសមាជិកអាស៊ានទាំង១០, អង្គការយូណេស្កូ, តំណាងលេខាធិការអាស៊ាន, គ្រឹះស្ថានឯកជននិងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សរុបប្រមាណ១៤៥នាក់។

លទ្ធផលនៃការជជែកពិភាក្សាក្នុងសិក្ខាសាលានេះ បានជួយដល់អាស៊ានក្នុងការកំណត់យុទ្ធសាស្ត្រ និងអនុសាសន៍សម្រាប់ការអភិវឌ្ឍវិស័យវប្បធម៌ និងសិល្បៈក្រោយការរីករាលដាលនៃជំងឺកូវីដ-១៩។ ព្រឹត្តិការណ៍នេះបានបាក់ផ្សាយអនឡាញតាមរយៈផេកផ្លូវការរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលមានអ្នកចូលទស្សនាចំនួន១៨០០នាក់៕

# មរតកកែវមណីមេខលា៖ ការចងចាំ ការផ្ទេរចំណេះដឹង និងការបន្តវេន នៃរបាំព្រះរាជទ្រព្យ

រយៈពេល១០ថ្ងៃ ពោលគឺពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលជាថ្នាលបណ្ដុះបណ្ដាលវិស័យសិល្បៈ និងវប្បធម៌កម្រិតឧត្ដមសិក្សារបស់រដ្ឋតែមួយគត់ បានសម្របសម្រួល និងផ្ដល់ទីតាំងសម្រាប់ប្រារព្ធព្រឹត្តិការណ៍សិក្ខាសាលាដ៏កម្រ និងប្រកបដោយគុណតម្លៃ និងមានអត្ថន័យជ្រាលជ្រៅបំផុត។





កិច្ចសម្ភាសគ្រូចាស់ៗនិងសិស្សគណរបស់ព្រឹទ្ធាចារ្យ ជា សាមី



រូបចម្លាក់ព្រឹទ្ធាចារ្យ ជា សាមី

សិក្ខាសាលាឈ្មោះថា "មរតកកែវមណីមេខលា" ឬជាភាសាអង់គ្លេស"Following Mekhala's Jewel" ជាការជួបជុំគ្នាឡើងវិញនៃសិស្សគណរបាំព្រះរាជទ្រព្យ ដែលធ្លាប់បានហាត់រៀនជាមួយព្រឹទ្ធាចារ្យ ជា សាមី ក្រោយរបបខ្មែរក្រហមក្នុងទសវត្សរ៍១៩៨០ និង១៩៩០។ ការជួបជុំគ្នានេះ គឺដើម្បីប្រមែប្រមូលឡើងវិញនូវក្បាច់ពិសេសៗនៃរបាំ ល្ខោន និងបច្ចេកទេសតួអង្គនាង និងរបាំ ដែលបង្ហាត់បង្រៀន និងបង្កើតដោយព្រឹទ្ធាចារ្យ ជា សាមី តាមរយៈការចងចាំរបស់សិស្សគណ និងគ្រូចាស់ៗដែលជាអតីតសហការី ធ្លាប់បានបង្រៀន និងសម្ដែងជាមួយលោកព្រឹទ្ធាចារ្យ។ សកម្មភាពសំខាន់ៗនោះរួមមានការសម្ភាសសិស្ស និងគ្រូរបាំ, ការជួយគ្នារម្លឹកឡើងវិញនូវក្បាច់

និងកាយវិការរបាំសំខាន់ៗ, ការហាត់សម និងសម្តែងរបាំ ពិសេសរបាំមណីមេខលាដែលព្រឹទ្ធាចារ្យ ជា សាមី ធ្លាប់ជាអតីតតួអង្គមណីមេខលាដ៏ល្បីល្បាញ។ រស្មីនៃកែវមណីនៅតែរះភ្លឺចិញ្ចាចចិញ្ចែងក្នុងដួងចិត្តសិស្សគណរបស់គាត់ជានិច្ច។ នៅថ្ងៃចុងក្រោយ គឺការប្រារព្ធពិធីសំពះគ្រូ ដែលមានការអញ្ជើញចូលរួមយ៉ាងច្រើនកុះករពីព្រឹទ្ធាចារ្យ,គ្រូរបាំ,អតីតនិស្សិតនិងនិស្សិតសាលារបនាច្រើនជំនាន់ និងគ្រប់ជំនាញ ដែលពុំធ្លាប់មានពីមុនមក។ សកម្មភាពសិក្ខាសាលាទាំងមូល ត្រូវបានថតជាវីដេអូ និងរូបថតទុកជាឯកសារ ហើយយកទៅតម្កល់ទុកនៅមជ្ឈមណ្ឌលសោតទស្សន៍បុប្ផាណា ដើម្បីឱ្យសិល្បករជំនាន់ក្រោយបានទស្សនា, ស្រាវជ្រាវ និងរៀនសូត្រ។

សកម្មភាពហាត់សមរម្លឹកក្បាច់និងរបាំដែលបង្កើត
និងដំឡើងដោយព្រឹទ្ធាចារ្យ ជា សាមី







សូមរម្លឹកដែរថា ព្រឹទ្ធាចារ្យ ជា សាមី ជាអតីតសិល្បការិនីរបាំព្រះរាជទ្រព្យនៃព្រះបរមរាជវាំងដ៏ល្បីនាស.វ.ទី២០និងជាគ្រូបង្ហាត់របាំនៅសាលាវិចិត្រសិល្បៈរហូតដល់ថ្ងៃលាចាកលោកទៅក្នុងឆ្នាំ១៩៩៤។ អតីតសិស្សដែលមកចូលរួមមាន១១រូប គឺមកពីប្រទេសអាមេរិច, កាណាដា, បារាំង,

នាយកដ្ឋានសិល្បៈទស្សនីយភាព, សាលាមធ្យមវិចិត្រសិល្បៈ, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងស្ថាប័នដទៃទៀត។ សិក្ខាសាលានេះផ្ដួចផ្ដើមឡើងដោយបណ្ឌិត Toni Shapiro-Phim និងអ្នកគ្រូ Huy Serey Phousita។ ព្រឹត្តិការណ៍ដ៏មានតម្លៃនេះ ឆ្លុះបញ្ចាំងពីការលះបង់របស់គ្រូក្នុងការខិតខំផ្ទេរបំណេះដឹង និងការតស៊ូព្យាយាមរបស់សិស្សក្នុងការហាត់រៀន ព្រមទាំងបង្ហាញពីការបងបាំនិងការដឹងគុណដ៏ជ្រាលជ្រៅបំផុតរបស់សិស្សគណបំពោះគ្រូបាអាចារ្យរបស់ខ្លួន។







សកម្មភាពហាត់សមរម្លឹកក្បាច់
និងរបាំដែលបង្កើត និងដំឡើង
ដោយព្រឹទ្ធាចារ្យ ជា សាមី

# បេតិកភណ្ឌឯកសារកម្ពុជា៖
## ការរក្សាទុកការចងចាំពីអតីតកាល

"បេតិកភណ្ឌឯកសារ" គឺសំដៅលើកេរដំណែល ឬសម្បត្តិឯកសារបន្សល់ពីអតីតកាល ពោលគឺជាសំណុំនៃព័ត៌មាននៅលើក្រដាស (កំណត់ហេតុសរសេរដៃ, សៀវភៅ, គំនូរ, ផែនទី...), ឯកសារសោតទស្សន៍ (ខ្សែភាពយន្ត, កាសែតបិត, រូបថត...) និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល។ ព័ត៌មានទាំងនោះទាក់ទងនឹងប្រវត្តិ, ដំណើរវិវឌ្ឍគំនិត, បទពិសោធនៃសហគមន៍, របកគំហើញ និងសមិទ្ធផលរបស់សង្គមមនុស្សដែលបានបន្សល់ដល់សហគមន៍ពិភពលោកនាពេលបច្ចុប្បន្ន និងពេលអនាគត។

កន្លងមក កម្ពុជាបានបញ្ចូលបេតិកភណ្ឌឯកសារបំនួនបីដែលមានតម្លៃជាសកលក្នុង "បញ្ជីស្មារតីបងចាំពិភពលោក" រួមមាន បណ្ណសារសារមន្ទីរទួលស្លែងក្នុងបញ្ជីថ្នាក់អន្តរជាតិ នៅឆ្នាំ២០០៩, ឯកសារសំឡេងនិទានរឿងរាមកេរ្តិ៍ដោយតាគ្រុឌក្នុងបញ្ជីថ្នាក់តំបន់ នៅឆ្នាំ២០១៤ និងរឿងអ៊ីណាវបុស្បា (Panji tales manuscripts) នៅឆ្នាំ២០១៧ ក្នុងបញ្ជីរួមជាមួយប្រទេស៤ទៀត គឺឥណ្ឌូនេស៊ី, ម៉ាឡេស៊ី, ហូឡង់ និងអង់គ្លេស។



តាគ្រុឌកំពុងនិទានរឿងរាមកេរ្តិ៍ឱ្យអ្នកស្រុកស្តាប់



ឯកសាររាជកិច្ចនិងរដ្ឋកិច្ចកម្ពុជា



រូបលេខ១៖ បណ្ណសារទួលស្លែង

ដូចដែលបញ្ជាក់ខាងដើម បេតិកភណ្ឌឯកសារគឺជាកេរដំណែលរបស់មនុស្សជាតិដែលរក្សាទុកនូវការចងចាំ អាចឱ្យយើងមើលត្រឡប់ទៅអតីតកាល ដើម្បីធ្វើឱ្យជីវិតបច្ចុប្បន្នរបស់យើងបានប្រសើរ និងអាចសម្លឹងមើលទៅអនាគតដោយភាពអង់អាចតាមរយៈការចងចាំដ៏យូរអង្វែង។ តួយ៉ាងបណ្ណសារទួលស្លែងបង្ហាញពីការចងចាំមួយដែលមិនអាចបំភ្លេចបានអំពីឧក្រិដ្ឋកម្មដ៏ឃោរឃៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលនាំឱ្យយើងចៀសវាងមិនឱ្យសង្គ្រាមកើតជាថ្មីទៀត។ ដោយយល់អំពីគុណតម្លៃបេតិកភណ្ឌឯកសារ គណៈកម្មាធិការជាតិស្មារតីចងចាំពិភពលោកកម្ពុជា បានគិតគូរនូវគោលនយោបាយគ្រប់គ្រង, ប្រមូលឯកសារ, លើកកម្ពស់ការអភិរក្ស និងធានាបាននូវការប្រើប្រាស់បេតិកភណ្ឌឯកសារនោះជាអចិន្ត្រៃយ៍សម្រាប់មនុស្សគ្រប់គ្នា។ កិច្ចការដំបូង ក្រុមការងារបានសហការគ្នារៀបចំសិក្ខាសាលាចំនួនពីរលើក ដើម្បីផ្សព្វផ្សាយអំពីបេតិកភណ្ឌឯកសារ និងកម្មវិធីស្មារតីចងចាំពិភពលោក និងប្រមូលព័ត៌មានដើម្បីរៀបចំបញ្ជីសម្រង់បេតិកភណ្ឌឯកសារថ្នាក់ខេត្ត ឬថ្នាក់ជាតិ។







សិក្ខាសាលាផ្សព្វផ្សាយអំពីបេតិកភណ្ឌឯកសារកម្ពុជាដែលបានចុះក្នុងបញ្ជី “ស្មារតីបងចាំពិភពលោក” និងការបង្កើតទម្រង់ពាក្យស្នើសុំចុះបេតិកភណ្ឌឯកសារក្នុងបញ្ជីស្មារតីបងចាំពិភពលោកថ្នាក់ជាតិ



ទន្ទឹមនឹងនេះ ក្រុមការងារក៏បានចុះទស្សនកិច្ចដល់ទីតាំងរក្សាបេតិកភណ្ឌឯកសារ ក្នុងគោលបំណងស្វែងយល់បន្ថែមអំពីកិច្ចការពារ ថែរក្សា និងអភិរក្សបេតិកភណ្ឌឯកសារដែលមានរក្សាទុកនៅទីនោះ។ គោលដៅអនាគត ក្រុមការងារគិតគូរអំពីការរៀបចំបញ្ជីបេតិកភណ្ឌឯកសារថ្នាក់ជាតិ និងសៀវភៅគោលការណ៍ណែនាំស្តីពីការស្នើសុំបញ្ចូលបេតិកភណ្ឌឯកសារ



ទស្សនកិច្ចដល់ទីតាំងរក្សាបេតិកភណ្ឌឯកសារ
នៅមជ្ឈមណ្ឌលសោតទស្សន៍បុប្ផាណា, បណ្ណាសារដ្ឋានជាតិ, សារមន្ទីរទួលស្លែង





ក្នុងបញ្ជីសា្មរតីបងបាំពិភពលោកថ្នាក់ជាតិ។ បញ្ជីបេតិកភណ្ឌឯកសារថ្នាក់ជាតិនេះ នឹងអាចជាបញ្ជីត្រៀមសម្រាប់ចុះបញ្ជីថ្នាក់តំបន់ក៏ដូចជាថ្នាក់អន្តរជាតិ ហើយក៏នឹងអាចទុកជាឯកសារសម្រាប់ការសិក្សាស្រាវជ្រាវរបស់អ្នកជំនាន់នេះ ក៏ដូចជាអ្នកជំនាន់ក្រោយដែរ។

# ការអភិរក្សនិងផ្សព្វផ្សាយ
# មរតកវប្បធម៌រូបី

# ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ
## នៅបុរាណដ្ឋានប្រាសាទសំបូរព្រៃគុក

ទន្ទឹមនឹងការអភិរក្សនិងការស្រាវជ្រាវ ការចូលរួមចំណែកបង្កើនការយល់ដឹងនិងបណ្តុះបណ្តាលធនធានមនុស្ស ក៏ជាបក្ខវិស័យក្នុងក្របខ័ណ្ឌនៃផែនការរយៈពេលវែងរបស់អាជ្ញាធរជាតិសំបូរព្រៃគុក (អ.ជ.ស.ព.) ដែលផ្តួចផ្តើមឡើងសម្រាប់និរន្តរភាពក្នុងការការពារការថែរក្សា និងការអភិរក្សរមណីយដ្ឋានសំបូរព្រៃគុក។ ចាប់ពីឆ្នាំ២០១៧មក ការផ្ទេរបំណេះជំនាញនានាក្នុងកិច្ចអភិរក្សដល់ប្រជាពលរដ្ឋក្នុងរមណីយដ្ឋាន ការផ្សព្វផ្សាយដល់សិស្សមធ្យមសិក្សា និងប្រជាពលរដ្ឋអំពីបេតិកភណ្ឌវប្បធម៌និងតំបន់ការពាររមណីយដ្ឋាន ព្រមទាំងការបណ្តុះបណ្តាលដល់និស្សិតលើការស្រាវជ្រាវបុរាណវិទ្យា និងអភិរក្សប្រាសាទសម័យមុនអង្គរ ក៏បានចាប់ផ្តើមអនុវត្តដំណាលៗគ្នាដែរ។

## ការផ្សព្វផ្សាយដល់សិស្ស

ក្នុងទស្សនវិស័យផ្តល់ការយល់ដឹងអំពី "បេតិកភណ្ឌវប្បធម៌សំបូរព្រៃគុក" ដល់យុវជនជំនាន់ក្រោយ នាយកដ្ឋានបុរាណវិទ្យានិងរមណីយដ្ឋាន បានអនុវត្តជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៩មក (លើកលែងតែអំឡុងពេលរីករាលដាលជំងឺកូវីដ-១៩ប៉ុណ្ណោះ)។ កម្មវិធីនេះធ្វើឡើងក្រោមកិច្ចសហការជាមួយគ្រឹះស្ថានអប់រំនានា ដើម្បីផ្តល់បំណេះដឹងទូទៅអំពីបេតិកភណ្ឌវប្បធម៌បន្ថែមពីលើកម្មវិធីសិក្សា សម្រាប់សិស្សានុសិស្សតាមសាលាមធ្យមសិក្សាក្នុងតំបន់





សកម្មភាពផ្សព្វផ្សាយដល់សិស្សានុសិស្សអំពីបេតិកភណ្ឌវប្បធម៌ប្រាសាទសំបូរព្រៃគុក

រមណីយដ្ឋាន។ លើសពីនេះ កម្មវិធីនេះក៏ជាជំហានមួយសម្រាប់ទាក់ទាញចំណាប់អារម្មណ៍សិស្សានុសិស្សឱ្យចាប់យកឯកទេសជំនាញណាមួយក្នុងវិស័យវប្បធម៌និងសិល្បៈ សម្រាប់បន្តការសិក្សារបស់ខ្លួននៅកម្រិតឧត្តមសិក្សានាពេលអនាគត។

## ការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ

កម្មវិធីផ្សព្វផ្សាយសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់បុរាណដ្ឋានក៏ពុំខុសគ្នាពីការអប់រំផ្សព្វផ្សាយដល់សិស្សមធ្យមសិក្សានោះដែរ ពោលគឺដើម្បីផ្តល់បំណេះដឹងទូទៅផ្នែកបេតិកភណ្ឌ និងឱ្យប្រជាពលរដ្ឋក្នុងរមណីយដ្ឋានយល់ដឹងពីតំបន់ការពារនិងបទដ្ឋានគតិយុត្តនានា ដើម្បីចូលរួមចំណែកក្នុងកិច្ចការពារ។ ការអប់រំផ្សព្វផ្សាយនេះក៏មានធ្វើតាមរយៈផ្ទាំងព័ត៌មាន និងការផលិតសម្ភារៈអប់រំជារូបភាពផ្សេងទៀត ដើម្បីឱ្យប្រជាពលរដ្ឋយល់ដឹងកាន់តែងាយស្រួលថែមទៀត។





សកម្មភាពផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីបេតិកភណ្ឌវប្បធម៌ប្រាសាទសំបូរព្រៃគុក

## ការបណ្តុះបណ្តាលដល់និស្សិត


ការបណ្តុះបណ្តាលដល់និស្សិត

ជារៀងរាល់ឆ្នាំនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសាកលវិទ្យាល័យផ្សេងៗទៀត ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៅប្រាសាទសំបូរព្រៃគុក ក្រោមប្រធានបទ “ការស្រាវជ្រាវបុរាណវិទ្យា និងការអភិរក្សស្ថាបត្យកម្ម”។ វគ្គនេះមិនត្រឹមតែផ្តល់ឱកាសឱ្យនិស្សិតបានរៀនសូត្រទ្រឹស្តីប៉ុណ្ណោះទេ តែបានអនុវត្តជាក់ស្តែងក្នុងការស្រាវជ្រាវនិងអភិរក្សប្រាសាទសម័យមុនអង្គរ ជាមួយអ្នកជំនាញ អ.ជ.ស.ព. និងពីសាកលវិទ្យាល័យ ព្រមទាំងស្ថាប័នអន្តរជាតិផ្សេងៗទៀត។ កម្មវិធីបណ្តុះបណ្តាលនេះ បានចូលរួមបំណែកបង្កើនធនធានមនុស្សសម្រាប់បន្តវេនក្នុងវិស័យស្រាវជ្រាវបុរាណវិទ្យា និងអភិរក្សទៅអនាគត។ កម្មវិធីនេះ គឺជាចក្ខុវិស័យនិងកម្មវិធីរយៈពេលវែងមួយរបស់ អ.ជ.ស.ព. ក្នុង “វិស័យសិក្សាសម័យមុនអង្គរ”។

## ការហ្វឹកហាត់ការងារដល់ប្រជាពលរដ្ឋ

កម្មវិធីនេះ គឺជាការហ្វឹកហាត់ និងបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋដែលកំពុងបំពេញការងារតាមការដ្ឋានអភិរក្សនានានៅសំបូរព្រៃគុក។ ក្រៅពីទទួលបានឱកាសការងារ និងប្រាក់បំណូល ពួកគាត់ក៏បានទទួលនូវជំនាញនិងបទពិសោធតាមរយៈការចូលរួមធ្វើកំណាយ ជួសជុលអភិរក្សវត្ថុសិល្បៈ និងប្រាសាទ។ ចក្ខុវិស័យរបស់អ.ជ.ស.ព. គឺថា “កិច្ចការពារ និងអភិរក្សប្រកបដោយចីរភាពនៅតំបន់ប្រាសាទសំបូព្រៃគុក ចាំបាច់ត្រូវមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន”៕





ការហ្វឹកហាត់ការងារដល់ប្រជាពលរដ្ឋនៅតំបន់បេតិកភណ្ឌវប្បធម៌ប្រាសាទសំបូរព្រៃគុក

# កំណាយស្រាវជ្រាវ
## នៅបុរាណដ្ឋានទួលកុកក្រួស

ទួលកុកក្រួស គឺជាបុរាណដ្ឋានមួយក្នុងចំណោមបុរាណដ្ឋានទាំង៤៧៦ ដែលបានរកឃើញក្នុងខេត្តព្រៃវែង។ ទួលនេះស្ថិតនៅភូមិខ្ទយ សង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។




រូបភាពពីលើអាកាសបង្ហាញទីតាំងទួលកុកក្រួស

ក្រុមការងាររបស់នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យាបានចុះទៅធ្វើកំណាយស្រាវជ្រាវ ក្នុងគោលបំណងសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យបុរាណវិទ្យា ដើម្បីចងក្រងទុកជាឯកសារ និងផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវមួយនេះជូនសាធារណជនឱ្យយល់ពីតម្លៃនៃសម្បត្តិវប្បធម៌ជាតិ។

ការធ្វើកំណាយស្រាវជ្រាវនៅស្ថានីយទួលកុកក្រូសនេះ មានចំនួន៣រណ្ដៅ (កំណាត់ពីត្បូងទៅជើង) ដែលស្ថិតក្នុងចំណុចនិយាមការ WGS 1984 UTM Zone 48N X 540450 Y 1272777។ រណ្ដៅទី១ ទំហំ ២ម៉ x២ម៉, រណ្ដៅទី២ ទំហំ ១ម៉x ២ម៉ និងរណ្ដៅទី៣ ទំហំ ១ម៉x២ម៉។ បំពោះវត្ថុសិល្បៈរកឃើញ ក្រុមការងារបានកត់ត្រាក្នុងក្រដាសព័ត៌មាន និងសិក្សាវិភាគឱ្យត្រូវគ្នានឹងលេខបញ្ជីវត្ថុ។



ការវាស់វែងកំណត់រណ្ដៅកំណាយ



ការកត់ត្រាចុះបញ្ជីវត្ថុសិល្បៈ

ក្រោយពីបានធ្វើកំណាយទាំង៣រណ្ដៅរួចមក ក្រុមការងារបានរកឃើញរបតាសម្ព័ន្ធនៃការលើកដីទួល តាមរយៈការសិក្សាស្រទាប់ដី និងប្រទះឃើញបំណែកកុលាលភាជន៍ជាច្រើន ក្នុងនោះមានកុលាលភាជន៍ខ្មែរ (ភាជន៍រឹង ភាជន៍ផុយ) និងបំណែកកុលាលភាជន៍ចិន និងបំណែកឥដ្ឋដែលជាជញ្ជាំងឡដុតកុលាលភាជន៍។ ប្រភេទភាជន៍ផលិតក្នុងស្រុកមានកុណ្ឌី, ឆ្នាំងបាតរាក់ (ឆ្នាំងសម្ល), ផើង, ក្អម, ជើងក្រាន, ប៉ូ, ខ្ចប, ឰប, ដិន្លាប់។ បំពោះដិន្លាប់ស្រទាប់រលោងពណ៌ស, បានលាបទឹកថ្នាំពណ៌សនិងពណ៌ខៀវ, បានសេឡាដុន ដែលមាននៅស្ថានីយនេះប្រហែលជាមកតាមរយៈជំនួញផ្លូវសមុទ្រ។ លើសពីនេះ បានរកឃើញថ្មស្រទាប់ និងថ្មក្រួសស្ទឹង ប្រើជាឧបករណ៍រំលីងផ្ទៃភាជន៍, កម្ទេចលោហៈ និងឆ្អឹងសត្វដែលជាសំណល់អាហាររបស់មនុស្ស។ បំណែកនៅក្នុងឥដ្ឋ មានរកឃើញសំបកស្រូវ ដែលបង្ហាញពីផ្នែកកសិកម្មនៅតំបន់នេះ។



ការគូរស្រទាប់ដី



ការសិក្សា និងបែងចែកកុលាលភាជន៍



បំណែកកុលាលភាជន៍ដែលបានរកឃើញ

## ការកំណត់កាលបរិច្ឆេទ តាមរយៈការសិក្សាប្រៀបធៀបភាជន៍ បានបញ្ជាក់ថានៅបុរាណដ្ឋានទួលកុកក្រួសនេះប្រហែលជា៖

១. ប្រភេទភាជន៍កុល្លី ឆ្នាំងបាតរាក់ និងឆ្នាំងដីផ្សេងៗ ប្រហែលមានផលិតប្រើប្រាស់តាំងសម័យអាណាចក្រហ្វូណន ចាប់ពីស.វ.ទី៣ គ.ស. ដល់ស.វ.ទី៦គ.ស. និងបន្តប្រើរហូតដល់សម័យបេនឡាវាងស.វ.ទី៦គ.ស. ដល់ស.វ.ទី៨គ.ស.។

២. ប្រភេទភាជន៍មាន ថូ, ផើង, ក្រឡ, ខ្លប, ចោ និងពាងជាច្រើន ជាប្រភេទភាជន៍ផលិតក្នុងឡដែលបានផលិតនៅចុងស.វ.ទី៩គ.ស. ដល់ស.វ.ទី១៥គ.ស.។ លើសពីនេះ តាមក្បាច់លម្អលើថូ និងផើងរាងអក្សរ w បញ្ឈរ ប្រហែលនាំចូលមកប្រើប្រាស់នៅទួលកុកក្រួសនេះដែរ។

៣. ភាជន៍ជំនួញនាំចូលមកពីចិនមាន ដន្លាប់មានស្រទាប់រលោងពណ៌ស នៅក្នុងសន្តតិវង្សសុងនិងយន់ អាចផលិតនៅស.វ.ទី១២គ.ស. ដល់ស.វ.ទី១៣គ.ស.។ បន្ទាប់មកទៀត បានក្រឡមមានលាបទឹកថ្នាំពណ៌ស និងពណ៌ខៀវ (ពណ៌ក្បាល់) ចាប់ពីរាជវង្សម៉េង (ស.វ.ទី១៥គ.ស. ដល់ស.វ.ទី១៧គ.ស.) និងមានប្រើប្រាស់បានលាបទឹកថ្នាំពណ៌ស និងផាត់ពណ៌ខៀវ ផលិតក្នុងរាជវង្សឆេង (ស.វ.ទី១៧ គ.ស. ដល់ស.វ.ទី១៩គ.ស.)។ ដូច្នេះ នៅទួលកុកក្រូសនេះជាកន្លែងរស់នៅច្រើនជំនាន់ និងយូរអង្វែង ហើយទីនេះប្រហែលជាកន្លែងដែលបានបង្កើតឡផលិតភាជន៍ប្រើប្រាស់ក្នុងសហគមន៍មនុស្សរស់នៅក្បែរតំបន់ពួកគាត់។ នៅសម័យបុរាណការធ្វើដំណើរតាមផ្លូវទឹកមានសារសំខាន់ដោយមកតាមសមុទ្រចូលមកទន្លេមេគង្គ ហើយអាចចូលមកដល់ព្រៃវែងដោយដឹកភាជន៍មកដូរដូរ និងដោះដូរជាមួយអ្នកស្រុក។ ជាក់ស្តែងការប្រើប្រាស់កុលាលភាជន៍ បង្ហាញឱ្យឃើញពីទំនាក់ទំនងរបស់មនុស្សនៅសម័យនោះជាមួយនឹងមនុស្សមកពីទីឆ្ងាយ ដូចជាអ្នកជំនួញតាមសំពៅរបស់ចិន និងអ្នកក្នុងស្រុក។ បើយោងទៅលើការសិក្សាប្រៀបធៀបលើបំណែកកុលាលភាជន៍ជាច្រើន ដែលក្រុមការងារបានប្រទះឃើញពេលធ្វើកំណាយកន្លងមក ទួលនេះជាទីតាំងមនុស្សរស់នៅប្រហែលតាំងពីសម័យហ្វូណននិងបន្តគោរពបូជារហូតមកដល់ពេលបច្ចុប្បន្ន៕

# រាជធានីកោះកេរ
# និងសហគមន៍មនុស្សរស់នៅសម័យបុរាណ

កោះកេរ ឬឆោកគគីរ (ឆោកគិគ្យរ) ដែលគេដឹងតាមរយៈសិលាចារឹកភាសាខ្មែរបុរាណ ថាជារាជធានីសម័យអង្គរចន្លោះពីគ.ស.៩២៨ ដល់៩៤៤ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៤ និងបុត្រារបស់ព្រះអង្គហស៌វរ្ម័នទី២។ រាជធានីកោះកេរមានបុរាណដ្ឋានសរុបចំនួន១៦៩ ក្នុងនោះមានប្រាសាទចំនួន៧៦។ នៅឆ្នាំ២០១៨ អាជ្ញាធរជាតិព្រះវិហារបានចាប់ផ្តើមសិក្សាស្រាវជ្រាវសំណល់បុរាណវិទ្យាលើផ្ទៃដីផ្នែកខាងត្បូង ខាងលិចរហាល និងជុំវិញបរិវេណប្រាសាទធំ។ នៅឆ្នាំ២០២៣ ក្រុមការងារបានបន្តសិក្សាបន្ថែមនៅផ្នែកខាងត្បូងរហាល។ ភស្តុតាងដែលប្រមូលបាននិងសិក្សាវិភាគបង្ហាញថា ទីតាំងរាជធានីកោះកេរមានមនុស្សរស់នៅអស់ជាច្រើនសតវត្សរ៍ មុនពេលទីតាំងនេះត្រូវប្រែក្លាយទៅជារាជធានីនៅគ.ស.៩២៨។ ភស្តុតាងសំណល់បុរាណវិទ្យាដែលប្រមូលបានទាំងនោះ មានដូចជា បំណែកកុលាលភាជន៍, វត្ថុសិល្បៈធ្វើពីលោហធាតុ, បំណែកដីឥដ្ឋដុត, រចនាសម្ព័ន្ធថ្មភក់,




ផែនទីបង្ហាញរាជធានីកោះកេរ និងផ្លូវបុរាណ

ថ្មបាយក្រៀម, ទំនប់ស្ទាក់ទឹកបុរាណ, កម្រាលឥដ្ឋ, គ្រឿងថ្មបាយក្រៀមក្នុងរាជវាំង និងគ្រឿងបល្ល័ង្កលិង្គជាដើម។ បំណែកឯបំណែកកុលាលភាជន៍ភាគច្រើនបានរកឃើញនៅលើទួលនិងទំនប់ជុំវិញប្រាសាទបុរាណ ព្រមទាំងក្បែរត្រពាំង និងប្រឡាយ។



ផែនទីបង្ហាញពីទីតាំងសិក្សាផ្ទៃខាងលើ និងបុរាណដ្ឋាន

ការស្រាវជ្រាវនេះ បានក្លាយជាចំណុចចាប់ផ្ដើមពិចារណាឡើងវិញក្នុងប្រវត្តិសាស្ត្រ ជាពិសេសអតីតរាជធានីកោះកេរ ដោយពឹងផ្អែកលើការរៀបចំក្រុង, សហគមន៍មនុស្សរស់នៅបុរាណ, ប្រព័ន្ធធារាសាស្ត្របុរាណ, សំណង់ប្រាសាទ, សិលាចារឹក និងវត្ថុសិល្បៈផ្សេងៗទៀត។ ការវិភាគលើសហគមន៍មនុស្សរស់នៅសម័យបុរាណ ដោយផ្អែកលើវត្ថុសិល្បៈធ្វើពីដីឥដ្ឋដុតដូចជាកុលាលភាជន៍និងវត្ថុសិល្បៈផ្សេងៗនឹងអាចស្វែងយល់ពីបុព្វហេតុនៃការផ្លាស់ប្ដូររាជធានី ដោយយោងលើសក្ខានុពលបុរាណដ្ឋាន និងវត្ថុប្រើប្រាស់ប្រចាំថ្ងៃ។ តាមរយៈវត្ថុប្រើប្រាស់ទាំងអស់នោះក៏អាចបង្ហាញឱ្យយើងដឹងពីល្បាយប្រជាជនរស់នៅតាមដំណាក់កាលក្នុងសម័យនីមួយៗដែរ។

លទ្ធផលស្រាវជ្រាវសំណល់បុរាណវិទ្យា និងការធ្វើកំណាយ (តាមរយៈការយកសំណាកធ្យូងទៅវិភាគកាបូន ឬហៅថា C14) បញ្ជាក់ថានៅបន្លោះប្រាសាទធំ និងព្រះរាជវាំងមានសហគមន៍មនុស្សរស់នៅតាំងពីស.វ.ទី៧គ.ស.មកម្ល៉េះ។







សកម្មភាពប្រមូលទិន្នន័យ កត់ត្រា និងប្រមូលវត្ថុសិល្បៈតាមទួលបុរាណ



កុលាលភាជន៍ផុយ



កុលាលភាជន៍ពណ៌ត្នោត





កុលាលភាជន៍ពណ៌បៃតង





កុលាលភាជន៍ចិនសម័យសុង



កុលាលភាជន៍ចិនសម័យឆេង

ការស្រាវជ្រាវលើផ្ទៃដីនៅផ្នែកអាគ្នេយ៍របាល និងត្រពាំងអង្គខ្នារនៅឆ្នាំ២០២៣ បង្ហាញថា មានរបនាសម្ព័ន្ធសំណង់ថ្មបាយក្រៀម ទំនប់ដី និងទួលមនុស្សរស់នៅតាំងពីសម័យមុនអង្គរដោយផ្អែកលើការវិភាគកុលាលភាជន៍ដែលជាវត្ថុប្រើប្រាស់ប្រចាំថ្ងៃ។ បន្ថែមពីនោះក្រុមការងារក៏បានរកឃើញបំណែកកុលាលភាជន៍ដូចជាគ្រឿងប្រភេទរឹង កុលាលភាជន៍ពណ៌ត្នោត និងពណ៌បៃតង និងកុលាលភាជន៍ផុយគ្មានស្រទាប់រលោង។ បំណែកកុលាលភាជន៍ខ្មែរទាំងអស់នេះ បានបង្ហាញពីការធ្វើពាណិជ្ជកម្មក្នុងតំបន់ ដែលនាំយកមកពីឡនៅតំបន់អង្គរមានដូចជាឡបង្កោង, ឡថ្នល់ម្រេច, ឡថ្មដល់, ឡជើងឯក និងឡបុរីរម្យ និងបំណែកកុលាលភាជន៍ប្រហែល៥០ភាគរយផលិតនៅឡគោកដីឆ្នាំងតំបន់កោះកេរនេះផ្ទាល់។ បំណែកកុលាលភាជន៍ខ្មែរដែលប្រមូលបានក្នុងការស្រាវជ្រាវទាំងពីរលើកមានបំនួន១៥៥៥៥បំណែក សរុបទាំងមាត់ បាត និងបំណែកខ្លួន និងវត្ថុសិល្បៈផ្សេងៗមានដូចជាបំណែកឥដ្ឋចំនួន៧៤បំណែក, ដែកចំនួន៣, បំណែកដែបដិមា៤ និងបំណែកវត្ថុសិល្បៈផ្សេងៗចំនួន៥៣។





បំនួនអំបែងភាជន៍ និងភាគរយ



ផែនទីបង្ហាញពីទីតាំងកំណាយស្រាវជ្រាវ និងរយៈកម្ពស់ដីនៅរណ្ដៅទី១

បំណែកកុលាលភាជន៍ចិនប្រទះឃើញច្រើនផលិតក្នុងរជ្ជកាលសន្តតិវង្សសុង និងយាន (Qingbai, Green Glazed, Celadon) មានប្រភពមកពីឡ Dehua និងឡ Cizao សុងខាងត្បូង និងពីឡ Nan'an និង Xingzhou មកពីសុងខាងជើងដែលមានអាយុកាលរវាងស.វ.ទី១០ ដល់ទី១៣ នៃគ.ស.។ បំណែកកុលាលភាជន៍មួយចំនួនទៀតផលិតក្នុងរជ្ជកាលសន្តតិវង្សឆេង ដែលមកពីឡ Dehua និងJingdezhen ខេត្តហ្វូជៀន ក្វាងទុង និងខេត្តជៀនស៊ីប្រទេសចិនខាងត្បូង នៅស.វ.ទី១៧ ទៅទី១៩នៃគ.ស.។



ផែនទីបង្ហាញរណ្ដៅកំណាយទី១ និងស្រទាប់ដីចាក់បង្គរ

សង្ខេបមក ការស្រាវជ្រាវនិងការវិភាគសំណល់បុរាណវិទ្យាលើផ្ទៃដី និងសំណាកធ្យូងអាចឱ្យយើងដឹងថាមានទួលមនុស្សរស់នៅក្បែរត្រពាំង ទីទួលទំនប់បុរាណ និងអាចដឹងពីពេលវេលានៃការតាំងទីរបស់សហគមន៍មនុស្សរស់នៅសម័យបុរាណនៅកោះកេរតាំងពីមុនសម័យអង្គរនៅស.វ.ទី៧-៨នៃគ.ស រហូតដល់ស.វ.ទី១៩នៃគ.ស។

